ក

មាតិកា

I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

២៦-០២-២០១០ -ព្រះរាជក្រម នស/រកម/០២១០/០០៣ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី អស្សាមិករណ៍ ២១៨១

២-ព្រះរាជក្រឹត្យ

១៥-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៥៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក អ៊ូ សាងមីង (WU SHANG MING) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តឡុងជាង តៃវ៉ាន់ ២១៩៨

១៦-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៦៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក លី ចនឈីយ៉ាង (LEE JOHN CHI YEUNG) ជនជាតិចិន សញ្ជាតិកាណាដា កើតនៅក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ២១៩៩

១៦-០២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០២១០/១៧០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក គីម យូសុង (KIM YU SONG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅក្រុងព្យុងយ៉ាង សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ២២០០

០១-៣-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៣១០/១៨៧ ស្តីពី ការតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ចំនួន ០៩ នាក់ ២២០១

០១-៣-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៣១០/១៨៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះឯកឧត្តម ចំនួន ០៤ រូប ២២០៣

០១-៣-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៣១០/១៨៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ លោកបណ្ឌិត Thanavat Junchaya ២២០៤

០១-៣-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៣១០/១៩០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ ជូនចំពោះ លោកជំទាវ ឈរ ឫទ្ធី មាស សុគន្ធា ២២០៥

០១-៣-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៣១០/១៩១ ស្តីពី ការតាំងស៊ប់ :
១-មន្ត្រីរាជការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ចំនួន ១០៦ នាក់
២-មន្ត្រីរាជការ ទៅក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តម នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៩៤ នាក់
៣-មន្ត្រីរាជការ ស៊ីវិលក្នុងក្របខ័ណ្ឌ មន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ចំនួន ១២ នាក់ ២២០៦
០១-៣-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៣១០/១៩២ ស្តីពី ការតែងតាំង លោក សា លាង ជា ឧកញ៉ា ២២១៦

II_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

០៩-៣-២០១០ -អនុក្រឹត្យលេខ ៣០ អនក្រ.បក ស្តីពី ការបំពេញផ្ទៃដីបន្ថែមចំនួន ២៣,៧២ ហិកតាលើអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីកំណត់ផ្ទៃដីកោះពេជ្រ សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍កោះពេជ្រ ស្ថិតក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ២២១៧
២៥-០២-២០១០ -អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២២១៩
២៥-០២-២០១០ -អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២២២០
២៥-០២-២០១០ -អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២២២២
២៥-០២-២០១០ -អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២២២៣
២៥-០២-២០១០ -អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២២៦៣
២៦-០២-២០១០ -អនុក្រឹត្យលេខ ២២៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ត្រីវឌ្ឍនា ២២៦៤
២៦-០២-២០១០ -អនុក្រឹត្យលេខ ២២៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២២៦៦

២_សេចក្តីសម្រេច

០៥-៣-២០១០ -សេចក្តីសម្រេចលេខ ១៤ សសរ ស្តីពី ការកែសម្រួល និង រៀបចំការចងសម្ព័ន្ធមេត្រីភាព រវាងអង្គភាពកងទ័ព កងនគរបាលជាតិ ជាមួយស្ថាប័ន-អង្គភាពស៊ីវិល ២២៦៨

III_ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៨-០២-២០១០ -ប្រកាសលេខ ១០២ សហវ.ប្រក ស្តីពី ការផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនវិស្វកម្មឯករាជ្យសម្រាប់គ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ២២៧៥

២_គណៈកម្មការមូលបត្រកម្ពុជា

០១-១២-២០០៩ -ប្រកាសលេខ ០១១ គ ម ក ស្តីពី ការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករ ទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និង ទូទាត់មូលបត្រ និង ប្រតិបត្តិកររក្សាទុកមូលបត្រ ២២៨៧

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួង សុខាភិបាល

២៦-០១-២០១០ -ប្រកាសលេខ ០០៨ អបស.មព ស្តីពី បែបបទ និង ល័ក្ខខ័ណ្ឌបច្ចេកទេស ក្នុងការសុំបើក ឬ បិទ ឬ ប្តូរទីតាំង នៃមជ្ឈមណ្ឌលកែសម្ផស្ស និង មជ្ឈមណ្ឌលថែរក្សាសម្ផស្ស ២៣០១

ព្រះរាជក្រម

នស/រកម/០៣១០/០០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីអស្សាមិករណ៍ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១០៨/០០១/២០១០ ក.ធ.ច ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១០ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE LE MINISTRE ... ROYAL

ច្បាប់

ស្តីពី

អស្សាមិករណ៍

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះ មានគោលដៅកំណត់ពីអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីគោលការណ៍ យន្តការ នីតិវិធីនៃអស្សាមិករណ៍ និង សំណងឱ្យបានសមរម្យ និង យុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ និង គម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើឱ្យផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ច្បាប់នេះ មានគោលបំណងជាអាទិ៍ :

- ធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និង យុត្តិធម៌
- ធានាការទូទាត់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌
- បម្រើផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ
- ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

មាត្រា ៣.-

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះការធ្វើអស្សាមិករណ៍ដែលមានពាក់ព័ន្ធទៅនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះ មិនគ្របដណ្តប់លើកិច្ចព្រមព្រៀង ឬ អនុស្សារណៈ ស្តីពីការគាំពារវិនិយោគរវាងរាជរដ្ឋាភិបាល និង ប្រទេសជាដៃគូដែលមានចែងពីអស្សាមិករណ៍ទេ ។ ក្នុងករណីដែលពុំមានកិច្ចព្រមព្រៀងនេះទេ ឬ ក្នុងករណីដែលកិច្ចព្រមព្រៀង ឬ អនុស្សារណៈពុំមានចែងពីអស្សាមិករណ៍ គឺត្រូវស្ថិតនៅក្រោមអានុភាពនៃច្បាប់នេះ ។

មាត្រា ៤.-

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមានដូចតទៅ :

អស្សាមិករណ៍ សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬ សិទ្ធិប្រត្យក្ស លើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ រួមមាន ដីសំណង់ និង ដីណាំដាំដុះសម្រាប់បម្រើការស្ថាបនា ស្តារ និង ពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និង យុត្តិធម៌ ។

ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ សំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ រួមមាន កម្មសិទ្ធិករ ភោគី និង អ្នកមានសិទ្ធិទាំងឡាយនៅលើទីតាំងដីដែលជាអ្នកទទួលរងនូវផលប៉ះពាល់ដោយសារគម្រោងអស្សាមិករណ៍ ។

ផលប្រយោជន៍សាធារណៈ ឬ ទូទៅ សំដៅដល់ការប្រើប្រាស់ដី ឬ ទ្រព្យសម្បត្តិដោយសាធារណជនទូទៅ ឬ ដោយទីភ្នាក់ងារ ឬ ស្ថាប័នរដ្ឋ ឬ សាធារណៈ ។

តម្រូវការនៃផលប្រយោជន៍ជាតិ សំដៅដល់សកម្មភាព ឬ គម្រោងមានជាអាទិ៍ :

- ការសាងសង់ ស្តារ ថែទាំ ឬ ពង្រីក សំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬ ការងារសន្តិសុខ

- ការកាន់កាប់ដី ឬ ទ្រព្យសម្បត្តិ ដើម្បីអនុវត្តជាក់ស្តែងនយោបាយការពារបូរណភាពទឹកដី ។

អ្នកអនុវត្តគម្រោង សំដៅដល់រដ្ឋ សហគ្រាស និង គ្រឹះស្ថានសាធារណៈ អ្នកម៉ៅការ ឬវិនិយោគិន ។

គតិករ សំដៅដល់ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និង សិទ្ធិប្រើប្រាស់លើអចលនវត្ថុ ពីម្ចាស់អចលនវត្ថុ ។

បុគ្គលដែលធ្វើការរារាំង សំដៅដល់ រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនទាំងឡាយណាដែលជាមេក្លោង អ្នកសមគំនិត អ្នកញុះញង់ ដែលធ្វើសកម្មភាពដោយផ្ទាល់ ឬ ដោយប្រយោល ដោយគំនិតទុច្ចរិតក្នុងគោលដៅធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តសេចក្តីសម្រេចអស្សាមិករណ៍ ។

មាត្រា ៥.-

គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ មានជាអាទិ៍ :

ក- ការសាងសង់ ឬ ពង្រីកផ្លូវអេយស្ម័យយាន ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ដោយរួមទាំងរចនាសម្ព័ន្ធ និង ឧបករណ៍ ។

ខ- ការសាងសង់ ឬ ពង្រីកស្ថានីយថាមពល រចនាសម្ព័ន្ធ ឧបករណ៍ និង ខ្សែសម្រាប់ការបញ្ជូន និង ចែកចាយថាមពលអគ្គិសនី ។

គ- ការសាងសង់ ឬ ពង្រីកអគារ និង ឧបករណ៍សម្រាប់ប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ប្រព័ន្ធព័ត៌មានវិទ្យា ។

ឃ- ការសាងសង់ ឬ ពង្រីកផ្លូវ ថ្នាក្រុង ចំណតយានយន្ត ទីផ្សារ សួនច្បារ និង ទីលានសាធារណៈ ។

ង- ការសាងសង់ ឬ ពង្រីកប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធលូទឹកកខ្វក់ និង កន្លែងបម្រើសេវាសាធារណៈផ្សេងទៀត ។

ច- ការសាងសង់ ឬ ពង្រីកអគារ សម្រាប់អប់រំបណ្តុះបណ្តាលវិទ្យាសាស្ត្រ វប្បធម៌ ថែរក្សាសុខភាព សន្តិសុខសង្គម និង កីឡាដ្ឋានសម្រាប់សម្តែងជូនជាសាធារណៈ ។

ឆ- ការសាងសង់ ឬ ពង្រីកកន្លែងចម្រាញ់ និង កន្លែងប្រព្រឹត្តកម្ម សំណង់ ឧបករណ៍ សម្រាប់ការការពារធម្មជាតិ និង បរិស្ថាន ។

ជ- ការសាងសង់ ឬ ពង្រីកអគារ និង ឧបករណ៍សម្រាប់ស្រាវជ្រាវ និង សម្រាប់ការធ្វើអាជីវកម្មរ៉ែ និង ធនធានធម្មជាតិផ្សេងទៀត ។

ឈ- ការសាងសង់ ឬ ពង្រីកបណ្តាញឧស្ម័ន បណ្តាញបំពង់ប្រេងឥន្ធនៈ រោងចក្រចម្រាញ់ប្រេង រោងចក្រឃ្លាំងប្រេង និង បណ្តាញដទៃទៀត ។

ញ- ការសាងសង់ ឬ ពង្រីកអគារតាំងទីលំនៅដែលបណ្តាលមកពីការបំផ្លាញយ៉ាងធ្ងន់ធ្ងរពីធម្មជាតិមាន រញ្ជួយផែនដី ទឹកជំនន់ អគ្គិភ័យ និង គ្រោះបាក់ដីជាដើម និង ការរៀបចំសម្រាប់ការតាំងទីលំនៅឡើងវិញ ។

ដ- ការសាងសង់ ឬ ពង្រីកអគារសម្រាប់ការការពារ និង ការគាំពារប្រជាជន ។

ឋ- ការសាងសង់ ឬ ពង្រីកទីកន្លែងឆ្លងកាត់ព្រំដែន ។

ឌ- ការកសាង ពង្រីក ឬ ការរៀបចំសំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬ ការពារសន្តិសុខ ។

ឍ- ការបង្កើតឡើងថ្មីនូវតំបន់ការពារធនធានធម្មជាតិ ព្រៃឈើ បេតិកភ័ណ្ឌវប្បធម៌បុរាណវិទ្យា ឬ ការពារបរិស្ថាន ។

ណ- ការអនុវត្តតាមតម្រូវការរបស់ជាតិ តាមការកំណត់របស់រាជរដ្ឋាភិបាល។

ជំពូកទី ២
គោលការណ៍ទូទៅ

មាត្រា ៦.-

អសា្សមិករណ៍ អាចធ្វើលើអចលនវត្ថុមួយផ្នែកឬទាំងស្រុង ឬ លើសិទ្ធិប្រត្យក្សនៃអចលនវត្ថុ ។

មាត្រា ៧.-

មានតែរដ្ឋទេដែលជាអ្នកធ្វើអសា្សមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ។

អសា្សមិករណ៍អាចអនុវត្តទៅបាន លុះត្រាតែយកទៅអនុវត្តគម្រោង ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

មាត្រា ៨.-

រដ្ឋត្រូវតែទទួលទិញយកនូវចំណែកនៃអចលនវត្ថុ ដែលនៅសេសសល់ពីអសា្ស-មិករណ៍ ដោយថ្លៃសមរម្យ និង យុត្តិធម៌ តាមសំណើរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដែលពុំអាចរស់នៅក្បែរគម្រោងបាន ឬ ពុំអាចសាងសង់លំនៅឋានបាន ឬ ពុំអាចប្រកបអាជីវកម្មអ្វីផ្សេងទៀតបាន ។

មាត្រា ៩.-

អចលនវត្ថុដែលត្រូវបានដកហូតនេះ ត្រូវប្រើប្រាស់សម្រាប់តែក្នុងគោលដៅដែលបានគ្រោងទុកនៅក្នុងប្រកាសស្តីពីគម្រោងអសា្សមិករណ៍ ដើម្បីប្រយោជន៍សាធារណៈ ឬ តម្រូវការនៃផលប្រយោជន៍ជាតិប៉ុណ្ណោះ និង មិនអាចឱ្យទុកនៅចោលទំនេរដោយគ្មានមូលហេតុសមស្រប ឬ ផ្ទេរឱ្យឯកត្តជនណាម្នាក់ក្នុងគោលដៅបម្រើផលប្រយោជន៍ឯកជនបានឡើយ ។

អចលនវត្ថុដែលនៅសល់ពីតម្រូវការប្រើប្រាស់ ត្រូវផ្តល់អាទិភាពលក់ជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ តាមអត្រាតម្លៃនៃការទូទាត់សំណង ។ ក្នុងករណីដែលម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិមិនព្រមទទួលយកអចលនវត្ថុដែលសល់ពីតម្រូវការប្រើប្រាស់វិញទេ ត្រូវរក្សាទុកអចលនវត្ថុនោះជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

មាត្រា ១០.-

ក្នុងករណីពិសេស និង បន្ទាន់ ដែលសុវត្ថិភាពសាធារណៈតម្រូវ ដូចជា ប្រយុទ្ធប្រឆាំងគ្រោះអគ្គិភ័យ ទឹកជំនន់ ភ្លើងឆេះព្រៃ រញ្ជួយដី សង្គ្រាមដែលប្រុងនឹងកើតឡើង ឬ ការវាយប្រហារដោយភេរវកម្ម និង ស្ថានភាពផ្សេងៗទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល រាជរដ្ឋាភិបាលអាចធ្វើការដកហូតអចលនវត្ថុ ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុជាបណ្តោះអាសន្ន ដោយមិនចាំបាច់ធ្វើការពិគ្រោះយោបល់ឡើយ ហើយត្រូវប្រគល់ជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិវិញនៅពេលចប់ការដកហូតនេះ ។

ក្នុងករណីបន្ទាន់ និង ចាំបាច់ដែលផលប្រយោជន៍ជាតិតម្រូវ រាជរដ្ឋាភិបាលមានអំណាចឆន្ទានុសិទ្ធិក្នុងការធ្វើអស្សាមិករណ៍ ដោយមិនចាំបាច់រៀបចំធ្វើការពិគ្រោះយោបល់តាមនីតិវិធី ដូចមានចែងក្នុងជំពូកទី ៤ នៃច្បាប់នេះទេ ។

មាត្រា ១១.-

មុននឹងដំណើរការការងារអស្សាមិករណ៍ រាជរដ្ឋាភិបាលត្រូវគ្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់គ្រាន់ ហើយត្រូវផ្តល់ឥណទានឱ្យគ្រប់ចំនួន និង ទាន់ពេលវេលាជូនគណៈកម្មាធិការអស្សាមិករណ៍ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់យកទៅទូទាត់សំណងជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលរងនូវផលប៉ះពាល់ដោយសារអស្សាមិករណ៍ ។

ជំពូកទី ៣
យន្តការអស្សាមិករណ៍

មាត្រា ១២.-

គណៈកម្មាធិការអស្សាមិករណ៍មួយត្រូវបានបង្កើតឡើង និង ដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៣.-

អនុគណៈកម្មាធិការអស្សាមិករណ៍ ជាសេនាធិការនៃគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបានបង្កើតឡើង និង ដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និង មានតំណាងមន្ទីរជំនាញ អាជ្ញាធរពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

មាត្រា ១៤.-

គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវបានបង្កើតឡើង និង ដឹកនាំដោយតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង មានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

ជំពូកទី ៤
នីតិវិធីនៃអស្សាមិករណ៍
ផ្នែកទី ១
នីតិវិធីមុនអស្សាមិករណ៍

មាត្រា ១៥.-

អស្សាមិករណ៍ ត្រូវធ្វើឡើងដោយផ្អែកលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និង មានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួង ស្ថាប័នសាមី ។

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវរៀបចំសំណើស្តីពីគម្រោងអស្សាមិករណ៍ដាក់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និង សម្រេច ។

មាត្រា១៦.-

មុននឹងធ្វើសំណើស្តីពីគម្រោងអស្សាមិករណ៍ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើការអង្កេតជាសាធារណៈ ដោយត្រូវកត់ត្រាភិនភាគឱ្យបានលម្អិតចំពោះរាល់សិទ្ធិរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ លើអចលនវត្ថុ និង ទ្រព្យសម្បត្តិផ្សេងៗទៀតដែលមានជាប់ពាក់ព័ន្ធនឹងការផ្តល់សំណង ព្រមទាំងត្រូវកត់ត្រានូវរាល់បញ្ហាពាក់ព័ន្ធ ។

ក្នុងការធ្វើការអង្កេតនេះ គណៈកម្មាធិការអស្សាមិករណ៍ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងកម្រិតអាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និង តំណាងភូមិ ឬ សហគមន៍ដែលរងនូវអស្សាមិករណ៍ ដើម្បីផ្តល់ពត៌មាន ជាក់លាក់ ច្បាស់លាស់ និង ទទួលបាននូវមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធអំពីសំណើនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

ដើម្បីកំណត់ពេលវេលាដកហូត ឬ ទីកន្លែងដែលផ្តល់ថ្មី ឬ សំណង គណៈកម្មាធិការអស្សាមិករណ៍ ត្រូវសាកសួរគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យបានគ្រប់ជ្រុងជ្រោយ អំពីបញ្ហាអចលនវត្ថុ ដែលពាក់ព័ន្ធនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានាដាក់ជូន និង សុំការសម្រេចពីរាជរដ្ឋាភិបាល ។

មាត្រា១៧.-

ផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល គណៈកម្មាធិការអស្សាមិករណ៍ត្រូវចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលក្នុងនោះត្រូវជម្រាបដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិឱ្យបានដឹងអំពីអចលនវត្ថុដែលជាកម្មវត្ថុនៃការដកហូតនោះ និង ត្រូវចែងអំពីគោលបំណង នៃការដកហូតកម្មសិទ្ធិ និង/ឬ សិទ្ធិលើអចលនវត្ថុឱ្យបានច្បាស់លាស់ ដោយអនុវត្តតាមនីតិវិធី ដូចខាងក្រោម :

ក- កំណត់អំពីកម្មវត្ថុនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ទីតាំងគម្រោង និង រយៈពេលសម្រាប់អនុវត្តគម្រោង និង អាជ្ញាធរមានសមត្ថកិច្ច ដែលមានសិទ្ធិធ្វើបំរើធ្វើការដកហូតកម្មសិទ្ធិ និង/ឬ សិទ្ធិ ឬ ទ្រព្យសម្បត្តិឯកជន

ខ- កំណត់អំពីសំណងសមរម្យ និង យុត្តិធម៌

គ- កំណត់រយៈពេលនៃបណ្តឹងតវ៉ា

ឃ- ផ្ញើសេចក្តីប្រកាសទៅដល់គ្រប់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិដោយភ្ជាប់នូវលិខិតថតចម្លងនៃច្បាប់នេះ

ង- ដាក់ស្លាកសម្គាល់ថា អចលនវត្ថុនេះជាកម្មវត្ថុត្រូវដកហូតសម្រាប់បម្រើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ

ច- ផ្សព្វផ្សាយសេចក្តីប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយ

ឆ- បិទផ្សាយសេចក្តីប្រកាសនៅសាលាឃុំ សង្កាត់ ពាក់ព័ន្ធនឹងទីតាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ហើយសេចក្តីប្រកាសនេះត្រូវផ្សព្វផ្សាយជូនដល់ប្រជាជនដែលមានអចលនវត្ថុពាក់ព័ន្ធដោយមេភូមិ ។

មាត្រា ១៨.-

បន្ទាប់ពីទទួលបាននូវសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិអាចធ្វើបណ្តឹងសុំឱ្យមានការអង្កេត ដើម្បីឱ្យដឹងថាជាតម្រូវការមួយចាំបាច់ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិពិតប្រាកដមែន ឬ ក៏អាចបង្វែរទីតាំងគម្រោងទៅកន្លែងណាផ្សេងវិញបាន ។ បណ្តឹងនេះអាចធ្វើឡើងតាមរយៈមេធាវី ឬ តំណាងរបស់ខ្លួន ។

បណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបានទទួលសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ជូនចំពោះគណៈ-កម្មាធិការដោះស្រាយបណ្តឹងតវ៉ា ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។ ខ្លឹមសារសំខាន់ៗនៃបណ្តឹងមាន ជាអាទិ៍ :

- ឈ្មោះម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាសយដ្ឋាន និង លេខទូរស័ព្ទ
- មូលហេតុនៃការធ្វើបណ្តឹង
- ការរៀបរាប់អំពីលក្ខណៈស្របច្បាប់នៃដីនោះ
- ផលប្រយោជន៍របស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិនៅលើដីដែលត្រូវដកហូតនោះ ។

ប៉ុន្តែម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិមិនអាចធ្វើពាក្យបណ្តឹងតវ៉ាសុំឱ្យមានធ្វើការអង្កេតបានទេ ចំពោះតម្រូវការសម្រាប់កិច្ចអភិវឌ្ឍផ្លូវជាតិធំៗ ស្ពាន ផ្លូវរទេះភ្លើង ការតភ្ជាប់ ការចែកចាយបណ្តាញទឹក ភ្លើង បំពង់បង្ហូរប្រេងកាត បំពង់បង្ហូរទឹកកខ្វក់ ខ្សែបណ្តាញ ឬ លូមេបង្ហូរទឹក ប្រព័ន្ធធារាសាស្ត្រ ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានា និង សុំការសម្រេចពីរាជរដ្ឋាភិបាល ។

ផ្នែកទី ២
កិច្ចដំណើរការអស្សាមិករណ៍

មាត្រា ១៩.-

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុ អាចធ្វើទៅបាន លុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍បានផ្តល់សំណងឱ្យម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិជាមុន ដោយសមរម្យ និង យុត្តិធម៌ តាមគោលការណ៍ និង នីតិវិធីនៃការទូទាត់សំណង ដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ៤ នៃច្បាប់នេះ ។

ការដកហូតនៅតែអាចប្រព្រឹត្តទៅបាន ទោះបីទំនាស់នៅមិនទាន់បានដោះស្រាយរួចរាល់ហើយក្តី ។ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលបានទទួលប្រាក់សំណងតាមការកំណត់របស់គណៈកម្មាធិការអស្សាមិករណ៍ នៅតែមានសិទ្ធិបន្តការប្តឹងរបស់ខ្លួនទៅតាមនីតិវិធីនៃការជំទាស់ និង ការដោះស្រាយទំនាស់ដូចបានកំណត់ក្នុងមាត្រា ៣៤ ជំពូកទី ៦ នៃច្បាប់នេះ ។

មាត្រា ២០.-

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុដទៃទៀត ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ ។ សេចក្តីសម្រេចអស្សាមិករណ៍ ត្រូវកំណត់ជាអាទិ៍ :

- កម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុដែលត្រូវដកហូត
- សំណងដែលត្រូវទូទាត់
- កាលបរិច្ឆេទដែលតម្រូវឱ្យម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិធ្វើការរុះរើ ចាកចេញពីទីតាំង និង ធ្វើការប្រគល់អចលនវត្ថុ ជូនគណៈកម្មាធិការអស្សាមិករណ៍ ។

មាត្រា ២១.-

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចអស្សាមិករណ៍ និង ត្រូវផ្តល់សំណងគ្រប់ចំនួនដល់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ មុននឹងធ្វើអស្សាមិករណ៍ ។

ផ្នែកទី ៣
ការទូទាត់សំណងនៃអស្សាមិករណ៍

មាត្រា ២២.-

ប្រាក់សំណងដែលត្រូវផ្តល់ឱ្យទៅម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ត្រូវគិតតាមថ្លៃទីផ្សារ ឬ ថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

ថ្លៃទីផ្សារ ឬ ថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យមួយ តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍ ។

មាត្រា ២៣.-

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ មានសិទ្ធិទទួលបាននូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្តែង ដែលមានចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់មានសិទ្ធិទទួលបាននូវសំណងសមរម្យ និង យុត្តិធម៌ ។

មាត្រា ២៤.-

សំណងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬ ជាសិទ្ធិជំនួសទៅតាមភាពជាក់ស្តែង ដោយមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ និង ពីគណៈកម្មាធិការអស្សាមិករណ៍ ។

បែបបទ និង នីតិវិធីនៃការទូទាត់សំណង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ២៥.-

ប្រាក់សំណងត្រូវគិតតាមតម្លៃសំណងសរុប ដកចំនួនទឹកប្រាក់បន្ទុកពន្ធប្រថាប់ត្រា និង/ ឬ ពន្ធលើដីធ្លីមិនប្រើប្រាស់ដែលកន្លងមកមិនទាន់បានបង់ជូនរដ្ឋ ហើយគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបង់ប្រាក់ពន្ធកាត់ទុកទាំងនោះចូលថវិកាជាតិ តាមនីតិវិធីជាធរមាន ។

មាត្រា ២៦.-

ប្រាក់សំណងចំពោះកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុ មិនត្រូវបានគិតដល់ការប្រែប្រួលនៃតម្លៃដែលកើតមានឡើង ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍នោះឡើយ ដោយការប្រែប្រួលទាំងនោះអាចពាក់ព័ន្ធដល់ការផ្លាស់ប្តូរវិធានការបម្រុងផ្ទៃដីទុកដែលមានក្នុងផែនការនគរូបនីយកម្ម ដែលកំណត់តំបន់ប្រើប្រាស់ដីធ្លី ឬ ផែនការប្រើប្រាស់ដីធ្លីដែលបានអនុម័តត្រឹមត្រូវ ឬ ដោយការប្រែប្រួលនោះបណ្តាលមកពីសេចក្តីប្រកាស ស្តីពីគម្រោងអស្សាមិករណ៍ ។

មាត្រា ២៧.-

បន្ទាប់ពីទទួលបានប្រាក់សំណងគ្រប់ចំនួនរួចហើយ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ត្រូវទទួលខុសត្រូវក្នុងការថែរក្សា ស្នាក់អាស្រ័យ កាន់កាប់ និង ទទួលផលដែលលើសិទ្ធិ និង អចលនវត្ថុ រហូតដល់មានការទទួលយកអចលនវត្ថុទាំងនោះ ដោយគណៈកម្មាធិការអស្សាមិករណ៍ ។

មាត្រា ២៨.-

គណៈកម្មាធិការអស្សាមិករណ៍អាចទទួលយកអចលនវត្ថុ ឬ សិទ្ធិលើអចលនវត្ថុនោះ ក្រោយពី :

- បានអនុវត្តតាមនីតិវិធី និង លក្ខខណ្ឌដូចមានចែងក្នុងផ្នែកទី ១ និង ផ្នែកទី ២ ជំពូកទី ៤ នៃច្បាប់នេះ

- ការផ្តល់ប្រាក់សំណងត្រូវបានអនុវត្តតាមគោលការណ៍ និង នីតិវិធីដូចមានចែងក្នុងផ្នែកទី៣ ជំពូកទី ៤ នៃច្បាប់នេះ ។

មាត្រា ២៩.-

ភតិកៈអចលនវត្ថុដែលមានកិច្ចសន្យាត្រឹមត្រូវ ត្រូវទទួលបាននូវសំណងសម្រាប់ការរំខាននានា ពាក់ព័ន្ធនឹងការដកហូតជាអាទិ៍ ការរុះរើសំណង់ សម្ភារៈ ការដឹកជញ្ជូនទៅកាន់ទីតាំងថ្មី ។

ចំពោះភតិកៈអចលនវត្ថុដែលកំពុងប្រកបអាជីវកម្ម ត្រូវមានសិទ្ធិទទួលបាននូវសំណងលើផលប៉ះពាល់ដល់អាជីវកម្មនិងការឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និង យុត្តិធម៌ លើតម្លៃដើមទុនដែលបានចំណាយជាក់ស្តែង សម្រាប់សកម្មភាពនៃការប្រកបរបរអាជីវកម្មនោះ ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

ចំពោះការដកហូតយកទីតាំងដែលកំពុងមានសកម្មភាពអាជីវកម្ម ម្ចាស់អចលនវត្ថុត្រូវមានសិទ្ធិទទួលបានសំណងឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និង យុត្តិធម៌ លើតម្លៃនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ជាក់ស្តែង ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

ជំពូកទី ៥
អន្តរកាលនៃការកាន់កាប់ និង គ្រប់គ្រងអចលនវត្ថុ

មាត្រា ៣០.-

ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិពុំអាចលក់ ឬ ផ្ទេរអចលនវត្ថុនោះឱ្យអ្នកដទៃបានឡើយ ។ លិខិតឯកសារនានា និង នីតិវិធីទាំងអស់ដែលផ្ទុយនឹងបទប្បញ្ញត្តិនេះ ត្រូវចាត់ទុកជាមោឃៈ ។

ចំពោះការប្រើប្រាស់ដី ឬ អចលនវត្ថុពាក់ព័ន្ធ ត្រូវរក្សាលក្ខណៈ និង ទំហំប្រើប្រាស់ដូចមាននៅពេលចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ហើយមិនត្រូវសាងសង់សំណង់នៅលើដីនោះថែមទៀតឡើយ ។ សកម្មភាពណាដែលផ្ទុយនឹងបញ្ញត្តិខាងលើនេះ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មិនត្រូវមានសិទ្ធិទទួលបានសំណងលើការសាងសង់សំណង់ថ្មីបន្ថែមនោះឡើយ ។

មាត្រា ៣១.–

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាចកាន់កាប់អចលនវត្ថុទាំងនោះបានត្រឹមរយៈពេល ១ (មួយ) ខែ បន្ទាប់ពីគណៈកម្មាធិការអស្សាមិករណ៍បានទូទាត់សំណងគ្រប់ចំនួនស្របតាមនីតិវិធី ដូចមានចែងនៅក្នុងជំពូកទី ៤ នៃច្បាប់នេះ លើកលែងតែមានការព្រមព្រៀង ឬ មានការអនុញ្ញាតផ្ទុយពីនេះ ។

ក្នុងករណីម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិពុំព្រមចាកចេញពីទីកន្លែងនោះ គណៈ- កម្មាធិការអស្សាមិករណ៍អាចស្នើសុំទៅស្ថាប័នមានសមត្ថកិច្ច ឬ អាជ្ញាធរសាធារណៈ ដើម្បីចាត់វិធានការ តម្រូវឱ្យជននោះចាកចេញពីទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ ។

ជំពូកទី ៦

ការដោះស្រាយវិវាទ

មាត្រា ៣២.–

គណៈកម្មាធិការអស្សាមិករណ៍ និង គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា មានសមត្ថកិច្ចទទួលពិនិត្យ និង ដោះស្រាយបណ្ដឹងតវ៉ា ។

មាត្រា ៣៣.–

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលមិនយល់ស្របនឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ អាចប្ដឹងទៅគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា ។

មាត្រា ៣៤.–

ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្ដីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាចប្ដឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និង យុត្តិធម៌ ។

[illegible]បទ និង នីតិវិធីប្ដឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៧
ទោសប្បញ្ញត្តិ

មាត្រា ៣៥.-

មន្ត្រីមានសមត្ថកិច្ចដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាល ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀតស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

មាត្រា ៣៦.-

បុគ្គលណាដែលធ្វើការរារាំងដល់ការអនុវត្តសេចក្តីសម្រេចអស្សាមិករណ៍ដោយគំនិតទុច្ចរិត ធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តគម្រោងដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ដល់ ២.០០០.០០០ (ពីរលាន) រៀល ។

មាត្រា ៣៧.-

បុគ្គលណាដែលបានកាន់កាប់ ប្រើប្រាស់ដោយរំលោភបំពានលើទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន ។

ជំពូកទី ៨
អវសានប្បញ្ញត្តិ

មាត្រា ៣៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣៩.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

៣រ.ល.១០០២.១៧៩

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ:១៨៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ មីនា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អ៊ូ សាងមីង** (WU SHANG MING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៥៥ នៅខេត្តឡុងជាង តៃវ៉ាន់ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ៧. ១០០២.១៥៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០

លេខៈ ១៣៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ចនឈីយ៉ាង** (LEE JOHN CHI YEUNG) ជនជាតិចិន សញ្ជាតិកាណាដា កើតថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៣ នៅក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.១០០៤.១៧២

នរោត្តម សីហមុនី

លេខ:១៣៥ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

យ៉ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២១០/១៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គឹម យូសុង** (KIM YU SONG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៨៤ នៅក្រុងព្យុងយ៉ាង សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

ពរល.១០០៧.១៧៤

នរោត្តម សីហមុនី

លេខ: ១៣៦ ច.ល

ចំឡងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៣១០/២៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌ**មន្ត្រីបច្ចេកទេសជាន់ខ្ពស់** របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ ដូចមានរាយនាមខាងក្រោម :

១	**លឹម សុគ៌ាត្រា**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
២	**សូ យុនវិរក្ស**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៣	**កុយ សោភា**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៤	**រដ្ឋ ច័ន្ទសុវណ្ណ**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
[illegible]	**កុយ និន្នារ៉ា**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**

៦	**អ៊ី នីឡៃន**	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៧	**ញាន កន្និកា**	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៨	**សែន សុភាព**	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៩	**សូវ៉ាន់ គិមាន**	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១០

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបន្ទាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

ពរ/ល. ១០០៣.១៩០

លេខ: ១៨៧ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៣១០/១៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូនចំពោះ :

១- ឯកឧត្តមសាស្ត្រាចារ្យ **កើត មៀច**

២- ឯកឧត្តម **នេព លន់**

៣- ឯកឧត្តម **លឹម ជារាមាណី**

៤- ឯកឧត្តម **អ៊ុំ សុផល**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១០

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣រល.១០០៣.១៩៧

លេខ: ១៨៤ប.ល

ចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៣១០/២៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា** ជូនចំពោះ :

លោកបណ្ឌិត **Thanavat Junchaya**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១០

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣រ.ល.១០០៣.១៩៤

លេខ: ១៨៣ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ិន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៣១០/១៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន**
ថ្នាក់ **មហាសេរីវឌ្ឍន៍** ជូនចំពោះ

លោកជំទាវ **ឈរ ប៊ូរី មាស សុភា**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

ចរល.១០០៣.១៩៣

លេខ:១៨៧ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

នស/រកត/០៣១០/១៩១

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៩១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតាំងស៊ប់មន្ត្រីរាជការរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ទៅក្នុងឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដូចមានរាយនាមខាងក្រោម :

តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩ តទៅ				
១	**អឿ សារេត**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
២	**ម៉ៅ អេខឌី**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៣	**អ៊ុន ដ៏រ**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៤	**ម៉ុន ដា**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៥	**ភាន់ វណ្ណី**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៦	**គីម សុចិត្រា**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៧	**សាយ សុធុល**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៨	**ប៊ូ ចាន់ថន**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
៩	**យូ ចន្ថា**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
តាំងស៊ប់គិតចាប់ពីថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩ តទៅ				
១០	**ដួង ដាវី**	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
១១	**សុគន្ធ ពិដា**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
១២	**សុភាន ណារិទ្ធិ**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
១៣	**លីម ស៊ីថង**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
១៤	**សួរ សាន**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
១៥	**ថៅ ហ៊ីរ**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
១៦	**យូ ពិសិដ្ឋ**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
១៧	**ពាង ហ៊ាញ**	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ តទៅ				
១៨	**សំ ភូអ៊ី**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**
១៩	**សុគន្ធ តក្កី**	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ **១៤**

២០	ហេង លីទ្រី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២១	ជន ច័ន្ទសុគន្ធា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២២	យ៉ាងនី សុទាចា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
តាំងស៊ប់គិតចាប់ពីថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៩ តទៅ				
២៣	ម៉ុំ មករា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៤	រឿន សេរីវុធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៥	អ៊ុម ជីនិត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៦	សេង ស៊ីងហេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៧	ដេង ហេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៨	ប៉ែន ភក្ដដា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
២៩	នុត សោភ័ណ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣០	ហុង ណារ៉េត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣១	លី ប៊ុនថន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣២	ម៉ុំ ប៊ុណ្ណារ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៣	ទ៉ាន់ សាន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៤	ឈាន ឆាយា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៥	ខួន សត្យា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៦	កែ សុគា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៧	ម៉ែន សុដាន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩ តទៅ				
៣៨	សៀម សាន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៣៩	ឯម សោភ័ណ្ឌរិទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤០	អឿ គុមិន្ទ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤១	ជន លីន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤២	នុត រ៉ាទី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៣	តៀន មិនា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៤	តែម និត្យ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៥	លី និណាល់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

៤៦	ហាំង សុខសេរី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៧	អ៊ុំង យុន្ធាវី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៨	សាយ សុធន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៤៩	អ៊ិត ផល្លីន	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥០	ហ៊ុយ ច័ន្ទពិសី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥១	ម៉ូវ រដ្ឋា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥២	ម៉ឿង ឌីណា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៣	ឌួច សុផាត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៤	សូ សុធា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៥	ស៊ីវ យាង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៦	ប៉ែន យ៉ារីម	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៧	ច្វាន់ រតនា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៨	ហួយ ឈាងហ៊ន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៥៩	នួន ពន្លក	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦០	តូ សេរី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦១	កួយ សុគុំ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦២	ទ្រាំ សុគា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៣	ធីម ប៊ុនធឿន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៤	ដេត ច័ន្ទវីរៈ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៥	ហ៊ន វណ្ណា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៦	ជ័យ រ៉ានិត្យ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៧	ហ៊ី ហាក់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៨	នង សុវណ្ណវិសាល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦៩	ជា តារម្យ	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧០	សុខ ស៊ីនួន	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧១	ថេង ពេជ្រសិទ្ធី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧២	ប៊ុក ម៉ីយ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៣	ព្រហ្ម ចាន់រិទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

៧៤	ឈុប សុខុម	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៥	ឡា សាលិម	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៦	លី សុតាឡែន	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៧	តាន់ បូនុំ	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៨	ពេជ្រ បញ្ញា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧៩	ខួន ឧត្តម	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨០	តាំង សុភ័ក្ត្រ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨១	ល័ស ច័ន្ទពិដោរ	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨២	សំ ស្រីណាត	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨៣	ទ៉ា ពិសិដ្ឋ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨៤	មុត សុជីវ័ន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨៥	ថៃ ហេងដា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨៦	ឌី សុខសិរី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨៧	សំ ចាន់តិរម្យ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨៨	ភួង ប៊ុនធឿន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨៩	ពេជ្រ សម្ផស្ស	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩០	ពុក ស្រីណាន	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩១	ឆី ច័ន្ទសេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩២	សោម សុខធី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩៣	មាច វិសាល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩៤	គីស តារ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩៥	គឹម សិរីរត្ន៍	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩៦	អ៊ឹម ឡេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩៧	សោម ចលនា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩៨	ឈឿង ចាន់ធឿន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩៩	កើត តាន់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០០	ចាន់ ធានី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០១	តាន់ ប៊ុនធន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

១០២	សុខ ពុលីកា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០៣	សុក ពិសី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០៤	ចាន់ វណ្ណះ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០៥	ជួ ដេខ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០៦	ជ័យ សុឆ្លា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

មាត្រា ២ : ត្រូវបានតាំងស៊ប់មន្ត្រីរាជការ ទៅក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តម នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានរាយខាងក្រោម :

តាំងស៊ប់គិតចាប់ពីថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៨ តទៅ				
១	ស៊ុត វ៉ាន់ឌី	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៩ តទៅ				
២	ដាន់ រ៉ាទុន្ធ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩ តទៅ				
៣	ស ខុទ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៤	កោ សត្រា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៥	ឡូយ នុតសិទ្ធីសិទ្ធី	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៦	ឈិន ចំរុង	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៧	ម៉ៅ គន្ធា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៨	អ៊ុំ តុណា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៩	សាន វណ្ណះ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
១០	ហេង ស៊ីវ៉ាន់ថា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
១១	គង់ ម៉េងហាក់	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
១២	លី រមណី	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
១៣	លាង ខ្លឹង	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
១៤	ឆាវ ស្រ៊ុនតាង	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
១៥	តូច ស៊ីណុ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
១៦	ឈាង សារិទ្ធ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
១៧	ថន រ៉ាដែន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤

១៨	អ៊ែន វិបុល	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
១៩	ម៉ន ឡាឡាត់	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
២០	ចេង យូរ៉ា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
២១	លៀង ពន្លក	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
២២	ឃឹម ខាស្វ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
២៣	ឃុន វិចិត្រ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
២៤	លឹម ទ៊ាន់ជា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
២៥	នាក់ ឈាន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
២៦	សួន ចំណា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
២៧	លឹម សោភ័ណ្ឌតារា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
២៨	លឹម សារេត	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
២៩	យាន គីមយ៉េង	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៣០	ជួប សម្បត្តិ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៣១	លឹម មករា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៣២	យឿន ប៊ូលីន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៣៣	តាំង ចិន្តា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៣៤	ជួន ជ័យពិសិដ្ឋ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៣៥	លុយ ខេមរ៉ាតជារិទ្ធ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៣៦	ចាំង សុផល	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៣៧	ឈឹង វិជ្ជា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៣៨	សេង វាសនា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៣៩	ថាយ គីមសាន	ស	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៤០	យ៉ាម យុទ្ធា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៤១	ដេង សុវណ្ណា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៤២	ហ៊ឹម សារឿន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៤៣	ទេង ស្រីសុខ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៤៤	ហៃ រតនា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៤៥	ស៊ីវ សុគុជឆរ៉ា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤

៤៦	គង់ សំណាង	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៤៧	ភារប៊ុត សុមលីន	ស	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៤៨	ម៉ម ផាន់នី	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៤៩	ឆ៉ត សុខចាន់	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៥០	វឿង ដាវី	ស	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៥១	លឹម នៃត្រី	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៥២	តឿក ជ្រួនពុទ្ធីរត្ន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៥៣	កែត ទុឡ្សី	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៥៤	យូ រ៉ាដែត	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៥៥	ជឹម ទិសី	ស	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៥៦	មន្ត រស្មី	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៥៧	ឌុច វណ្ណស៊ីដ្ឋ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៥៨	ថាន់ ទើង	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៥៩	ហ៊យ ចាន់ធី	ស	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៦០	ភារប៊ុត សុមឡាប	ស	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៦១	ទូ គីមហ៊ាង	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៦២	លន់ ពិសិដ្ឋ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៦៣	ឆា ស៊ុយឆុន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៦៤	គន សេងហ៊ន់	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៦៥	ហៀង សុខហ៊ី	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៦៦	ទ៉ាត ទ៊ុន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៦៧	ហេង សុវណ្ណា	ស	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៦៨	សេង ធា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៦៩	សុង គីមសាន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៧០	នន់ សុខបានហេង	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៧១	គួច ប៊ុនឆត	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៧២	ឡេង ពុទ្ធារិទ្ធ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៧៣	អោម ខុន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៧៤	ផន ផុន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៧៥	សឹង ស៊ីថារិទ្ធ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៧៦	នូ ទាសនា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៧៧	អេង គីមហុង	ស	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៧៨	គួច ច័ន្ទសំណាង	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៧៩	សុខ ស៊ីនឡេង	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៨០	ឡៃ ហ៊ាងលី	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៨១	នេត តុម	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៨២	អ៊ី រតនៈ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៨៣	ប្រុក ណាទ័រន់	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៨៤	សេង សុរិយា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៨៥	លី សុគី	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៨៦	ស៊ិន ទិបុល	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៨៧	ជា មុំរត្ន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៨៨	មាស សោភ័ណ្ឌ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៨៩	ឱ្ចន ហាំង	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៩០	ឃួន ពិសិដ្ឋ	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៩១	ហាន សេងហ៊ាន	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៩២	តេង សំរោត	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៩៣	ពៅ សេតារា	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤
៩៤	សៀង សោមព្រហស្ស	ប	គ្រូបង្រៀនកម្រិតឧត្តម	ថ្នាក់លេខ ១៤

មាត្រា ៣ : ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌ**មន្ត្រីសុខាភិបាលជាន់ខ្ពស់** របស់ក្រសួងសុខាភិបាល ដូចមានរាយនាមខាងក្រោម :

តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៨				
១	យូ ម៉ូលីន	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៣
តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៨				
២	លី គៀត	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៣

៣	សាន់ ចាន់ណា	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៣
តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩				
៤	ឆាយ ល័ក្ខណ៍	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៣
៥	ឆាយ សុខដាលីស	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៤
៦	ឈោយ ច័ន្ទសុភាព	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៤
៧	សុខ ប៊ុនសួរ	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៤
៨	ជា សាគុណ	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៤
៩	ថៃ សុខបញ្ញា	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៤
១០	ហ៊ិន សារ៉ាដេ	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៤
១១	អ៊ុម សុចិន្តា	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់	ថ្នាក់លេខ ១៤

- ត្រូវរាយការណ៍មកក្រុមការងារអន្តរក្រសួងឱ្យបានទាន់ពេលវេលាពីការលំបាក និងភាពមិនប្រក្រតី ដែលបង្កឡើងដោយបុគ្គលអភិវឌ្ឍអចលនវត្ថុដែលខ្លួនបំរើការងារជូន

- មិនត្រូវផ្តល់សេវាជូនបុគ្គលអភិវឌ្ឍអចលនវត្ថុណាដែលពុំទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ

- មិនត្រូវពន្យាការសំរេច ឬការបញ្ជាក់លើលិខិតស្នើសុំដកប្រាក់របស់អតិថិជនដោយពុំបានបញ្ជាក់ មូលហេតុឱ្យបានច្បាស់លាស់ឡើយ

- មិនត្រូវមានចេតនាពន្យារ ឬអូសបន្លាយការងារត្រួតពិនិត្យឡើយ ។

ប្រការ៧: - ការត្រួតពិនិត្យ

ក្នុងករណីមានការសង្ស័យ ប្រធានក្រុមការងារអន្តរក្រសួងអាចចាត់មន្ត្រីជំនាញរបស់ខ្លួនដើម្បីចុះ ត្រួតពិនិត្យដល់ទីកន្លែងលើឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងការងារវាយតម្លៃរបស់អ្នកកាន់អាជ្ញាប័ណ្ណ។ អ្នកកាន់ អាជ្ញាប័ណ្ណត្រូវសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីជំនាញរបស់ក្រុមការងារអន្តរក្រសួងក្នុងការ ពិនិត្យបញ្ជីស្នាម និងឯកសារផ្សេងៗ ។

ប្រការ៨: - ការដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តខុសឆ្គង

ក្រុមការងារអន្តរក្រសួង មានសិទ្ធិដកហូតការងារ ឬអាជ្ញាប័ណ្ណប្រកបសេវាកម្មជាវិស្វករឯករាជ្យ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនគោរពប្រតិបត្តិតាមការណែនាំដូចមានចែងក្នុងប្រកាសនេះ ឬមានចែងក្នុង វិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈនោះទេ ។ បន្ថែមលើនោះក្រុមការងារអន្តរក្រសួងត្រូវផ្ញើលិខិត ជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាអាណាព្យាបាលគ្រប់គ្រង លើវិជ្ជាជីវៈរបស់អ្នកកាន់អាជ្ញាប័ណ្ណឱ្យបានជ្រាបអំពីបទល្មើសដែលអ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្ត ដើម្បីចាត់ វិធានការទៅតាមផ្លូវច្បាប់ជាធរមាន ។

ប្រការ៩: - របាយការណ៍បញ្ចប់គម្រោង

ក្រុមហ៊ុនវិស្វកម្មឯករាជ្យត្រូវផ្តល់របាយការណ៍វាយតំលៃបញ្ចប់គម្រោងសាងសង់ របស់បុគ្គលអភិវឌ្ឍ អចលនវត្ថុ មកក្រុមការងារអន្តរក្រសួងឱ្យបានមុនពេលដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញលិខិតបិទការដ្ឋានសាងសង់។

ប្រការ១០: - ការអនុវត្តប្រកាស

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ គ្រប់នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធដទៃទៀតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណវិស្វកម្មឯករាជ្យ បុគ្គលអភិវឌ្ឍអចលនវត្ថុទាំងអស់ដែលពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន

« ដើម្បីជូនជ្រាប »

កន្លែងទទួល:

- ដូចមានក្នុងប្រការ ១០

« ដើម្បីអនុវត្ត »

- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រុមការងារអន្តរក្រសួង

ដើម្បីគ្រប់គ្រងការអភិវឌ្ឍអចលនវត្ថុ

វិធាននៃការប្រតិបត្តិ និង ក្រមសីលធម៌វិជ្ជាជីវៈ សំរាប់វិស្វករឯករាជ្យ

(Rule of Conduct & Code of Ethics for Independent Engineer)

វិធាននៃការប្រតិបត្តិ (Rule of Conduct)

វិស្វករដែលចង់ផ្តល់សេវាកម្មជាក្រុមហ៊ុនវិស្វកម្មឯករាជ្យ ត្រូវគោរពនូវវិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈដូចតទៅ ÷

វិធានទី ១ : ការចុះបញ្ជី (Registration)

វិស្វករដែលបញ្ចប់ការសិក្សា និងឆ្លងកាត់បទពិសោធន៍យ៉ាងតិច ៣ ឆ្នាំឡើងទៅក្នុងវិជ្ជាជីវៈរបស់ខ្លួន ប្រសិនបើចង់ក្លាយខ្លួនជាក្រុមហ៊ុនវិស្វកម្មឯករាជ្យត្រូវតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវដាក់ពាក្យសុំប្រកបសេវាកម្មផ្នែកនេះ មកក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ នៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

វិធានទី ២ : ភារកិច្ចវិជ្ជាជីវៈ (Professional duty)

ក្រុមហ៊ុនវិស្វកម្មឯករាជ្យត្រូវអនុវត្តភារកិច្ចវិជ្ជាជីវៈរបស់ខ្លួនដូចតទៅ ÷

២.១ ត្រូវអនុវត្តភារកិច្ចវិជ្ជាជីវៈឱ្យបានល្អជូនអតិថិជនរបស់ខ្លួនប្រកបដោយ ភាពជឿជាក់ ស្មោះត្រង់ សុចរិត កិត្តិយស និងវិជ្ជាជីវៈ និងត្រូវគោរពផលប្រយោជន៍ របស់សាធារណជន។

២.២ ត្រូវប្រកាន់យកនូវភារកិច្ចវិជ្ជាជីវៈ និងសកម្មភាពទាំងឡាយណាដែលផ្តល់នូវកេរ្តិ៍ឈ្មោះ កិត្តិយស និងជំនាញវិជ្ជាជីវៈដល់ខ្លួន ។

២.៣ មិនត្រូវទទួលយកនូវលាភការ ឬការអនុគ្រោះពីភាគីណាមួយដែលអាចជះឥទ្ធិពលលើទំនាក់ទំនងជាមួយអតិថិជនឡើយ ។

២.៤ត្រូវមានតម្លាភាព និងទទួលយកមកពិនិត្យឡើងវិញនូវការងារដែលខ្លួនបានធ្វើ ប្រសិនបើមានការស្នើសុំ ឬមានការតម្រូវដោយអតិថិជន ឬដោយអាជ្ញាធរមានសមត្ថកិច្ច ។

២.៥ ត្រូវបញ្ចូលក្នុងរបាយការណ៍នូវរាល់ឯកសារយោង អំណះអំណាង ដែលពាក់ព័ន្ធនឹងការសន្មត់ លក្ខខណ្ឌ ការតម្រូវ និងដែនកំណត់ដែលកើតឡើងពីការណែនាំរបស់ខ្លួន ឬព័ត៌មានដែលទទួលបានពីប្រភពខាងក្រៅ ។

២.៦ ត្រូវរក្សាឯកសារវាយតំលៃសំរាប់ធ្វើជាភស្តុតាងក្នុងការស៊ើបអង្កេត និងសំរាប់តម្រូវការផ្សេងៗទៀតតាមស្ថានភាពជាក់ស្តែង។

២.៧ ត្រូវបើកទស្សនៈវិស័យ និងបង្ហាញនូវគំនិតដែលខ្លួនយល់ថា មានចំណុចណាមួយមិនត្រឹមត្រូវដោយបង្ហាញអំពីហេតុផលដែលនាំឱ្យខ្លួនយល់ឃើញយ៉ាងដូច្នេះផង ។

២.៨ ត្រូវទទួលខុសត្រូវទាំងស្រុងទៅលើកិច្ចការ និងរបាយការណ៍ដែលខ្លួនបានធ្វើ ។

២.៩ អ្នកចុះហត្ថលេខាលើរបាយការណ៍ទាំងអស់ត្រូវបង្ហាញអំពីសមាសភាពនៅក្នុងការងារនេះ ឬសមត្ថភាពទទួលខុសត្រូវក្នុងការងារចុះហត្ថលេខានេះ ។

២.១០ នៅពេលមានបណ្តឹង ឬមានបញ្ហាវិវាទនឹងក្រមសីលធម៌វិជ្ជាជីវៈនេះ ក្រុមហ៊ុនវិស្វកម្មឯករាជ្យទាំងអស់ត្រូវសហការផ្តល់ព័ត៌មានឱ្យក្រុមការងារអន្តរក្រសួងតាមស្ថានភាពជាក់ស្តែង។

២.១១ ត្រូវធ្វើបច្ចុប្បន្នកម្ម និងការអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីបង្កើននូវចំណេះដឹង និងសមត្ថភាពរបស់ខ្លួន ។

២.១២ ត្រូវផ្តល់សេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធិភាពខ្ពស់ ។

២.១៣ រាល់កិច្ចព្រមព្រៀងដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវារបស់ខ្លួនត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរដោយប្រើប្រាស់ពាក្យពេចន៍ច្បាស់ៗ និងងាយយល់ព្រមទាំងមានការបញ្ជាក់ឱ្យបានច្បាស់លាស់នូវរាល់លក្ខខណ្ឌ កាតព្វកិច្ច និងរាល់អនុសាសន៍ ដែលភាគីពាក់ព័ន្ធបានព្រមព្រៀងគ្នា ។ រាល់កិច្ចព្រមព្រៀងដែលបានពិនិត្យ និងចុះហត្ថលេខាត្រូវតែថតចំលងដើម្បីចែកជូនដល់ភាគីដែលពាក់ព័ន្ធ។

២.១៤ ត្រូវប្រកាន់ឯករាជ្យភាព និងមិនលំអៀងក្នុងការអនុវត្តកាតព្វកិច្ចវិជ្ជាជីវៈ និងមិនត្រូវៈ

- **ក.** យល់ព្រមទទួលកិច្ចការណាដែលប្រព្រឹត្តផ្ទុយទៅនឹងកាតព្វកិច្ចវិជ្ជាជីវៈដូចជាប្រតិបត្តិការគ្មានឯករាជ្យភាព និងមានភាពលំអៀងទៅភាគីណាមួយជាដើម។
- **ខ.** ធ្វើជាជំនាញការផងនិងជាមេធាវី(អ្នកបញ្ចុះបញ្ចូល)ផងនៅក្នុងរឿងតែមួយនោះទេ
- **គ.** យកវិជ្ជាជីវៈរបស់ខ្លួនទៅបំរើសេចក្តីត្រូវការរបស់អតិថិជនឬភាគីណាមួយផ្សេងទៀតដែលផ្ទុយនឹងក្រមសីលធម៌វិជ្ជាជីវៈនោះឡើយ។
- **ឃ.** ជឿលើព័ត៌មានទាំងឡាយណាដោយគ្មានការពិចារណា ឬការបញ្ជាក់អំពីប្រភពឱ្យបានច្បាស់លាស់នោះឡើយ ។

២.១៥ ថ្លៃឈ្នួលសេវាអាចចរចាជាមួយអតិថិជនតាមការព្រមព្រៀងគ្នាជាមូលដ្ឋានដោយមិនត្រូវៈ

- ក. រំលោភលើក្រមសីលធម៌វិជ្ជាជីវៈ វិធាននៃការប្រតិបត្តិ និងបទបញ្ញត្តិផ្សេងៗ
- ខ. ផ្អែកលើការកំណត់របស់អតិថិជន
- គ. ផ្អែកលើទំហំការងារដែលត្រូវទទួលខុសត្រូវ ។

២.១៦ មិនត្រូវរិះគន់ ឬធ្វេសប្រហែសក្នុងការងារដែលបង្កឱ្យមានគ្រោះថ្នាក់ប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលទៅលើកិត្តិយស ផលប្រយោជន៍ ឬអាជីពរបស់អ្នកដទៃទៀតឡើយ។

២.១៧ មិនត្រូវទទួលធ្វើការងារណាដែលមិនស្ថិតនៅក្នុងសមត្ថភាពវិជ្ជាជីវៈ ឬដែលខ្លួនមិនយល់ដឹងនោះឡើយ ។

២.១៨ មិនត្រូវណែនាំកិច្ចការណាដែលមិនមែនជារបស់ខ្លួនឡើយ លើកលែងតែមានចែងនៅក្នុងក្រមសីលធម៌វិជ្ជាជីវៈនេះ ។

២.១៩ មិនត្រូវធ្វើការបញ្ជាក់ទៅលើការងារណាដែលខ្លួនមិនបានធ្វើ ឬដែលខ្លួនមិនបានត្រួតពិនិត្យនោះឡើយ ។

២.២០ មិនត្រូវដណ្តើមកិច្ចការពីអ្នកដទៃតាមរយៈការប្រកួតប្រជែងថ្លៃឡើយ ។

២.២១ មិនត្រូវបង្ខិតបង្ខំដោយផ្ទាល់ ឬ ដោយប្រយោល ឬប្រើអំណាចទៅលើបុគ្គលណាមួយឡើយ ទោះបីប្រើរូបភាពផ្តល់លាភការ ឬផ្តល់ជាអំណោយ ឬជាការអនុគ្រោះអ្វីមួយ ឬអ្វីផ្សេងក្នុងគោលបំណងដើម្បីទទួលបានជោគជ័យក្នុងការងាររបស់ខ្លួនឡើយ។

២.២២ មិនត្រូវទទួលការងារពីអតិថិជនឡើយ ក្នុងករណីដែលខ្លួនមិនអាចបំពេញការងារតាមពេលកំណត់បាន។

<u>ទិដ្ឋភាពទី ៣</u> : ការត្រួតពិនិត្យ (Supervision)

ក. ក្រុមហ៊ុនវិស្វកម្មឯករាជ្យដែលទទួលខុសត្រូវលើការងារត្រួតពិនិត្យត្រូវ ÷

៣.១ ទទួលខុសត្រូវទាំងស្រុងចំពោះការចាត់តាំងបុគ្គលិកក្រោមឱវាទឱ្យទៅទទួលការងារអ្វីមួយជំនួសខ្លួន។

៣.២ ត្រួតពិនិត្យឱ្យបានល្អិតល្អន់មុននឹងបញ្ជាក់លើឯកសារការងារ។

៣.៣ ធានាថាការងារដែលខ្លួនទទួលខុសត្រូវត្រួតពិនិត្យនោះសមស្របទៅនឹងសមត្ថភាព និងចំណេះដឹងរបស់ខ្លួន។

៣.៤ ធានាថាបុគ្គលិកវិស្វករដែលធ្វើការឱ្យខ្លួនគឺមានសមត្ថភាព បទពិសោធន៍ការងារក្នុងជំនាញ និងចំណេះដឹងគ្រប់គ្រាន់ក្នុងការបំរើការងារជូនអតិថិជន ។

៣.៥ រក្សាឯកសារ និងលិខិតស្នាមពាក់ព័ន្ធទៅនឹងគម្រោងឱ្យបានត្រឹមត្រូវ។

៣.៦ ដឹងពីពេលវេលា និងតំលៃសំភារៈបរិក្ខាសំណង់ឱ្យបានច្បាស់លាស់នៅពេលដែលបញ្ជាក់ទៅលើលិខិតស្នើសុំដកប្រាក់របស់បុគ្គលអភិវឌ្ឍអចលនវត្ថុ ។

ខ. ក្រុមហ៊ុនវិស្វកម្មឯករាជ្យដែលទទួលខុសត្រូវលើការងារត្រួតពិនិត្យមិនត្រូវ ÷

៣.១ ធ្វើការបញ្ជាក់លើឯកសារហួសពីការងារដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបានធ្វើឡើយ។

៣.២ ធ្វើការបញ្ជាក់ដោយខុសពីការងារដែលបានធ្វើឡើយ(អ្វីបានធ្វើ អ្វីមិនបានធ្វើ)។

៣.៣ ចេញលិខិតបញ្ជាក់ការងារដែលមិនស្ថិតនៅក្នុងជំនាញរបស់ខ្លួនឡើយ។

៣.៤ ទទួលខុសត្រូវត្រួតពិនិត្យការងារការដ្ឋាន ដែលមានបុគ្គលិកមិនមានលក្ខណៈសម្បត្តិបទពិសោធន៍ការងារក្នុងជំនាញ និងសមត្ថភាពគ្រប់គ្រាន់។

៣.៥ ពន្យារការសម្រេច ឬការបញ្ជាក់លើលិខិតស្នើសុំដកប្រាក់របស់អតិថិជនដោយពុំបានបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ឡើយ។

៣.៦ មានចេតនាពន្យារ ឬអូសបន្លាយការងារត្រួតពិនិត្យឡើយ ។

ទិដ្ឋានទី ៤: ការតម្រូវដោយក្រុមការងារអន្តរក្រសួង (Working Group Requirements)

៤.១ ក្រុមហ៊ុនវិស្វកម្មឯករាជ្យមិនត្រូវផ្តល់សេវាជូនបុគ្គលអភិវឌ្ឍអចលនវត្ថុណាដែលពុំទាន់មានអាជ្ញាប័ណ្ណអភិវឌ្ឍអចលនវត្ថុឡើយ ។

៤.២ ក្រុមហ៊ុនវិស្វកម្មឯករាជ្យត្រូវ ÷

ក. ធ្វើវិញ្ញត្តិដល់ក្រុមការងារអន្តរក្រសួង (ដោយមូលហេតុសមរម្យ/កំណត់ពេលវេលាច្បាស់លាស់) នូវការប្រែប្រួល ឬការយឺតយ៉ាវលើសេវារបស់ខ្លួន។

ខ. ផ្តល់នូវឯកសារដែលខ្លួនបានត្រួតពិនិត្យពេញលេញមកក្រុមការងារអន្តរក្រសួងឱ្យបានទាន់ពេលវេលា ។ ឯកសារនោះត្រូវតែបញ្ជាក់ថា ការងារដែលខ្លួនបានចុះត្រួតពិនិត្យពិតជាត្រឹមត្រូវ និងច្បាស់លាស់តាមលទ្ធផលការងារដែលបុគ្គលអភិវឌ្ឍអចលនវត្ថុបានអនុវត្តមែន។

គ. រាយការណ៍មកក្រុមការងារអន្តរក្រសួងឱ្យបានទាន់ពេលវេលាពីការលំបាក និងភាពមិនប្រក្រតី ដែលបង្កឡើងដោយបុគ្គលអភិវឌ្ឍអចលនវត្ថុដែលខ្លួនបំរើការងារជូន។

ទិដ្ឋានទី ៥ : ក្រមសីលធម៌វិជ្ជាជីវៈ (Code of Ethics)

ក. ក្រុមហ៊ុនវិស្វកម្មឯករាជ្យត្រូវ ÷

៥.១ គោរពទៅតាមវិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈនេះ ។

៥.២ មានការយល់ដឹង និងការទទួលខុសត្រូវខ្ពស់ដូចមានចែងក្នុងវិធាននៃការប្រតិបត្តិនេះ។

៥.៣ ចេះកំណត់ និងពិចារណាឱ្យបានត្រឹមត្រូវនូវទំនាស់ផលប្រយោជន៍ទាំងឡាយណាដែលអាចកើតមាននៅក្នុងអំឡុងពេលប្រតិបត្តិការរបស់ខ្លួន ។ ក្នុងករណីដែលពិនិត្យឃើញថា មានទំនាស់ផលប្រយោជន៍នោះ ក្រុមហ៊ុនវិស្វកម្មឯករាជ្យមិនត្រូវប្រតិបត្តិការសេវាកម្មឡើយ លើកលែងតែភាគីពាក់ព័ន្ធនឹងទំនាស់នោះអនុញ្ញាតឱ្យខ្លួនបន្តអនុវត្តកិច្ចការនេះ។

៥.៤ ផ្តល់សេវាកម្មតាមជំនាញ វិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីផ្តល់ការជឿជាក់លើវិជ្ជាជីវៈរបស់ខ្លួនដល់អតិថិជន និងសាធារណជន ។

ខ. ក្រុមហ៊ុនវិស្វកម្មឯករាជ្យមិនត្រូវ ÷

បង្ហាញព័ត៌មានសម្ងាត់របស់អតិថិជនខ្លួនឡើយ លើកលែងតែមានការយល់ព្រមជាមុនពីអតិថិជន ឬមានការតម្រូវពីអាជ្ញាធរមានសមត្ថកិច្ចទើបអាចបង្ហាញព័ត៌មានសម្ងាត់នោះបាន។

ជំពូកទី ៦ : ការល្មើសទៅនឹងវិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈ (Violate to the Rule of Conduct & Code of Ethics)

ករណីមិនគោរពប្រតិបត្តិតាមការណែនាំដែលមានចែងក្នុងវិធាននៃការប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈនេះទេ ក្រុមការងារអន្តរក្រសួងមានសិទ្ធិដកហូតការងារ ឬអាជ្ញាប័ណ្ណប្រកបអាជីវកម្មជាក្រុមហ៊ុនវិស្វកម្មឯករាជ្យមកវិញ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១០

អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជា

ប្រធានក្រុមការងារអន្តរក្រសួង ដើម្បីគ្រប់គ្រង ការអភិវឌ្ឍអចលនវត្ថុ

ងី តាយី

គណៈកម្មការមូលបត្រកម្ពុជា

លេខៈ ០៦៦.............គ ម ក

លិខិតចូល

ថ្ងៃទី០៣...ខែ០៣...ឆ្នាំ២០១០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រកាស

ស្តីពី

ការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និង ប្រតិបត្តិកររក្សាទុកមូលបត្រ

*****

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃ ទី ២៧ ខែ តុលា ឆ្នាំ ២០០៩

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវ នីតិវិធីដើម្បីផ្តល់ការអនុញ្ញាតឱ្យបុគ្គលធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬ ប្រតិបត្តិកររក្សាទុកមូលបត្រ និងកំណត់អំពីកាតព្វកិច្ចរបស់រាល់ប្រតិបត្តិករ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

ប្រការ ២.-

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-ច្បាប់ (Law) សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-អនុក្រឹត្យ (Anukret) សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-ប្រព័ន្ធជាត់ទាត់និងទូទាត់ (Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ បំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញ ទៅមកបាន ដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានច្បាស់លាស់ និងធានាឱ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ។ ប្រព័ន្ធជាត់ទាត់និងទូទាត់ រួមមាន ៖

ក-ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ (Securities Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធជាត់ទាត់និងទូទាត់ដើម្បីធ្វើការផ្ទាស់ប្តូរកម្មសិទ្ធិលើមូលបត្រ រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

ខ-ប្រព័ន្ធជាត់ទាត់និងទូទាត់សាច់ប្រាក់ (Cash Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធជាត់ទាត់និងទូទាត់ ដើម្បីធ្វើការផ្ទេរ ឬបង្វែរសាច់ប្រាក់រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

-បុគ្គលិកជាន់ខ្ពស់ (Senior Staff) សំដៅដល់បុគ្គលិកដែលមានឋានៈចាប់ពីអគ្គនាយករហូតដល់នាយកឬប្រធានផ្នែក រួមទាំងសវនករផ្ទៃក្នុង។

-ភាគហ៊ុនិកភាគតិច (Minority shareholder) សំដៅដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតតិចជាង ០៥ (ប្រាំ) ភាគរយ។

-អភិបាល (Director) សំដៅដល់ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលរបស់បុគ្គលដាក់ពាក្យស្នើសុំ ឬរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ។

ជំពូកទី ២
លក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាត

ប្រការ ៣.-

បុគ្គលដែលមានបំណងធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវដាក់ពាក្យស្នើសុំ និងត្រូវទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ក្រោយពីទទួលបានការសម្រេចពីការប្រជុំពេញអង្គរបស់ **គ.ម.ក.** ដោយអនុលោមតាមជំពូកទី៤នៃច្បាប់ ជំពូកទី៣នៃអនុក្រឹត្យ និងប្រកាសនេះ។

ប្រការ ៤.-

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវតែជាក្រុមហ៊ុនមូលធនដែលបង្កើត និងចុះបញ្ជីស្របតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឬជាក្រុមហ៊ុនដែលស្ថិតក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ លក្ខន្តិកៈរបស់បុគ្គលដាក់ពាក្យស្នើសុំ ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដែលកំណត់ក្នុងមាត្រា ១៩ នៃអនុក្រឹត្យ និងលក្ខខណ្ឌដូចខាងក្រោម ៖

១-នាមករណ៍ និងទម្រង់របស់ក្រុមហ៊ុន។

២-ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនត្រូវមានទីតាំងក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-កម្មវត្ថុអាជីវកម្ម។

៤-ដើមទុនជារូបិយវត្ថុជាតិ ៖

ក-ក្នុងករណីស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវមានចំនួនមិនតិចជាង ៤០.០០០.០០០.០០០ (សែសិបពាន់លាន) រៀល។

ខ-ក្នុងករណីស្នើសុំធ្វើជាប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវមានចំនួនមិនតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល។

គ-ក្នុងករណីស្នើសុំធ្វើជាប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវមានចំនួនមិនតិចជាង ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល។

ឃ-ក្នុងករណីស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ និងប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវមានចំនួនមិនតិចជាង ៨០.០០០.០០០.០០០ (ប៉ែតសិបពាន់លាន) រៀល។

៥-ចំណាត់ប្រភេទនិងចំនួនភាគហ៊ុន រួមទាំងតម្លៃចារឹកក្នុងមួយភាគហ៊ុន ដោយបញ្ជាក់ឱ្យបានច្បាស់នូវនីតិវិធី និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃដើមទុនដែលបង់ចូលជាភាគទុនរបស់ភាគហ៊ុនិកនីមួយៗ។

៦-ឈ្មោះ អាសយដ្ឋានពិតប្រាកដ និងចំណែកហ៊ុនរបស់ភាគហ៊ុនិកស្ថាបនិក ឬភាគហ៊ុនិកដែលមានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើន។

៧-សិទ្ធិ និងកាតព្វកិច្ចរបស់ភាគហ៊ុនិក ពិសេសរបស់ភាគហ៊ុនិកភាគតិច។

៨-ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ដោយបញ្ជាក់ពីតួនាទីនិងការទទួលខុសត្រូវរបស់អភិបាលម្នាក់ៗ។ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនត្រូវមានអភិបាលយ៉ាងតិចបំផុតចំនួន ០៥ (ប្រាំ) រូប។

៩-វិធាន និងយន្តការនៃការត្រួតពិនិត្យនិងដោះស្រាយទំនាស់ផលប្រយោជន៍ដែលអាចកើតមាននៅក្នុងក្រុមហ៊ុន។

១០-នីតិវិធីនៃការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានដែលពាក់ព័ន្ធ។

១១-នីតិវិធីនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងមហាសន្និបាតភាគហ៊ុនិក។

ប្រការ ៥.-

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវ ៖

១-មានធនធានគ្រប់គ្រាន់ ដែលរួមមាន ៖

ក-ទ្រព្យគ្រប់គ្រាន់ និងត្រូវបានគ្រប់គ្រងត្រឹមត្រូវសម្រាប់ធ្វើប្រតិបត្តិការ។

ខ-ធនធានមនុស្សប្រកបដោយចំណេះដឹង សមត្ថភាព និងបទពិសោធន៍ខ្ពស់សមស្របនឹងមុខតំណែងនីមួយៗរបស់ក្រុមហ៊ុន។

គ-ប្រព័ន្ធ និងយន្តការសម្រាប់ធ្វើប្រតិបត្តិការដែលទទួលបានការអនុញ្ញាត។

ឃ-ប្រព័ន្ធទ្រទ្រង់ (Back-up System) សមស្រប ដើម្បីធានាបាននូវប្រតិបត្តិការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

២-មានរចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុនមួយ ដែលអាចធានាបាននូវគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងអភិបាលកិច្ចសាជីវកម្មល្អ។ ក្នុងករណីស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ និងប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងប្រតិបត្តិការនីមួយៗដាច់ដោយឡែកពីគ្នា។

៣-មានសវនកម្មផ្ទៃក្នុង រួមទាំងវិន័យនិងនីតិវិធីនៃការអនុវត្តសវនកម្មផ្ទៃក្នុង និងគណៈកម្មាធិការសវនកម្ម។

ប្រការ ៦.-

បុគ្គលដាក់ពាក្យស្នើសុំ បុគ្គលដែលត្រូវតែងតាំងជាអភិបាលនិងបុគ្គលិកជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

១-មានលក្ខណសម្បត្តិនិងអត្តចរិតល្អ ដូចមានចែងក្នុងមាត្រា៤២ នៃអនុក្រឹត្យ។

២-មិនធ្លាប់ត្រូវបានប្រកាសក្ស័យធន ឬមិនធ្លាប់បង្កឱ្យក្រុមហ៊ុនមួយឬច្រើនឈានទៅរកភាពក្ស័យធននៅក្នុងឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៣-មិនធ្លាប់ប្រព្រឹត្តអំពើអ្វីដែលនាំឱ្យប៉ះពាល់ដល់ដំណើរការទីផ្សារមូលបត្រ ឬនៅក្នុងវិស័យហិរញ្ញវត្ថុ។

៤-មិនធ្លាប់ត្រូវបានដកហូតតំណែង ឬបណ្តេញចេញពីតំណែងឬពីទីផ្សារ ដោយយោងតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធ។

៥-មិនធ្លាប់ប្រព្រឹត្តអ្វីដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។

ប្រការ ៧.-

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រត្រូវ ៖

១-មានចំនួនភាគហ៊ុនភាគច្រើនដាច់ខាតកាន់កាប់ដោយប្រតិបត្តិករទីផ្សារមូលបត្រ។

២-មានភាគហ៊ុនដទៃទៀតដែលកាន់កាប់ដោយក្រុមហ៊ុនមូលបត្រ ស្ថាប័នហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** ក្នុងករណីដែលប្រតិបត្តិករទីផ្សារមូលបត្រជាភាគហ៊ុនិកភាគច្រើនដាច់ខាត។

ភាគហ៊ុនរបស់បុគ្គលដាក់ពាក្យស្នើសុំ ធ្វើជាប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ អាចផ្ទេរបានតែទៅក្នុងរង្វង់ប្រតិបត្តិករទីផ្សារ-មូលបត្រ ក្រុមហ៊ុនមូលបត្រ ស្ថាប័នហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។ ប៉ុន្តែប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវរក្សាចំនួនភាគហ៊ុនអប្បបរមាក្នុងកម្រិតភាគច្រើនដាច់ខាត។

ប្រការ ៨.-

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវបំពេញបែបបទនៃពាក្យស្នើសុំទៅតាមទម្រង់ដែលបានកំណត់ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖

១-វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម និងប័ណ្ណប៉ាតង់ ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៣-លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៤-លិខិតបញ្ជាក់ពីដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ។

៥-បញ្ជីរាយនាមភាគហ៊ុនិក ដោយបញ្ជាក់ពីចំនួនហ៊ុន និងភ្ជាប់មកជាមួយនូវអត្ត-សញ្ញាណបណ្ណឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខាឬស្នាមម្រាមដៃរបស់ភាគហ៊ុនិកនីមួយៗ។

៦-បញ្ជីរាយនាមអភិបាលក្រុមហ៊ុន ដោយបញ្ជាក់ពីតួនាទីនិងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃរបស់អភិបាលនីមួយៗ ព្រមទាំងលិខិតថ្កោលទោស។

៧-បញ្ជីរាយនាមបុគ្គលិកជាន់ខ្ពស់ទាំងអស់របស់ក្រុមហ៊ុន ដោយបញ្ជាក់ពីតួនាទី និងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខាឬស្នាមម្រាមដៃរបស់បុគ្គលិកជាន់ខ្ពស់នីមួយៗ ព្រមទាំងលិខិតថ្កោលទោស។

៨-បញ្ជីរាយនាមបុគ្គលដែលមានបំណងធ្វើជាសមាជិក ឬអ្នកចូលរួមក្នុងទីផ្សាររបស់បុគ្គលដាក់ពាក្យស្នើសុំ។

៩-ផែនការអាជីវកម្មសម្រាប់រយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។

១០-ផែនការគ្រប់គ្រងហានិភ័យ និងផែនការយថាភាព (Contingency Plan)។

១១-វិធានប្រតិបត្តិការ ដែលក្នុងនោះមានចែងនូវវិធាននិងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ប្រតិបត្តិករ វិធាននិងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាពនិងការចូលរួមក្នុងទីផ្សារ និងលក្ខន្តិកៈរបស់ប្រតិបត្តិករដែលបុគ្គលស្នើសុំធ្វើប្រតិបត្តិការ។ ករណីស្នើសុំធ្វើប្រតិបត្តិករទីផ្សារមូលបត្រ វិធានប្រតិបត្តិការត្រូវចែងបន្ថែមនូវវិធាននៃការចុះបញ្ជីនៅទីផ្សារមូលបត្រ។

ប្រការ ៩.-

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ផ្តល់ឯកសារនិងបំភ្លឺនូវចំណុចឬព័ត៌មានផ្សេងទៀតតាមការចាំបាច់ ដើម្បីធានាថាបុគ្គលដាក់ពាក្យស្នើសុំបំពេញបានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ។

ប្រការ ១០.-

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំការអនុញ្ញាតដោយផ្អែកលើមូលហេតុដូចខាងក្រោម ៖

១-បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញនូវលក្ខខណ្ឌណាមួយ ដែលមានចែងក្នុងប្រកាសនេះ ឬសេចក្តីណែនាំផ្សេងទៀតដែលធ្វើនៅក្រោមប្រកាសនេះ ឬបទប្បញ្ញត្តិជាធរមានដែលពាក់ព័ន្ធផ្សេងទៀត។

២-ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ទៅ **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស។

៣-បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬរំលាយអាជីវកម្ម។

៤-សេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល មិនត្រូវបានអនុវត្តទាំងស្រុងឬមួយផ្នែកដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។

៥-បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំ៖

ក-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ខ-បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិ ដែលការពារសាធារណជនឱ្យចៀសផុតពីការខាតបង់ផ្នែកហិរញ្ញវត្ថុ ដោយសារតែភាពមិនស្មោះត្រង់ ឬអសមត្ថភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលនោះក្នុងការផ្តល់សេវាហិរញ្ញវត្ថុឬក្នុងការគ្រប់គ្រងក្រុមហ៊ុន។

គ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀត ដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិត និងភាពដែលអាចទុកចិត្តបានផ្នែកហិរញ្ញវត្ថុរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌនៃការអនុញ្ញាត ប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។

៦-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុងឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ)ឆ្នាំ ចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-នៅពេលកើតមានហេតុការណ៍ណាមួយដែលអាច៖

ក-នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំមិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។

ខ-ឆ្លុះបញ្ចាំងពីភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្ម របស់បុគ្គលដាក់ពាក្យស្នើសុំ។

៨-បុគ្គលដាក់ពាក្យស្នើសុំ មាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ ឬ

ហិរញ្ញប្បទានភាវរកម្ម ឬការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវបដិសេធផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងមិនបានផ្តល់ឱកាសឱ្យបុគ្គលដាក់ពាក្យស្នើសុំធ្វើការពន្យល់។

ជំពូកទី ៣
ការផ្តល់ការអនុញ្ញាត

ប្រការ ១១.-

បន្ទាប់ពីបុគ្គលដាក់ពាក្យស្នើសុំបានបំពេញតាមគ្រប់លក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់បទប្បញ្ញត្តិជាធរមាននិងប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ **គ.ម.ក.** ត្រូវពិនិត្យនិងសម្រេចលើការស្នើសុំនោះ។ អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ការអនុញ្ញាត ឬជូនដំណឹងអំពីការបដិសេធ ដល់បុគ្គលដាក់ពាក្យស្នើសុំតាមការសម្រេចរបស់ **គ.ម.ក.**។ ក្នុងករណីអគ្គនាយកនៃ **គ.ម.ក.** ស្នើសុំឱ្យបុគ្គលដាក់ពាក្យស្នើសុំកែប្រែ ឬផ្តល់ព័ត៌មានបន្ថែម នោះលក្ខខណ្ឌពេលវេលាក្នុងការពិនិត្យនិងសម្រេចត្រូវគិតសាឡើងវិញ ចាប់តាំងពីកាលបរិច្ឆេទដែលព័ត៌មានទាំងនោះត្រូវបានផ្តល់ជូនដល់ **គ.ម.ក.**។

ប្រការ ១២.-

សុពលភាពនៃការអនុញ្ញាតមានរយៈពេលមិនកំណត់។

ប្រការ ១៣.-

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០.០០០.០០០ (ដប់លាន) រៀល នៅពេលដាក់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករនីមួយៗ។ ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាមានការបដិសេធលើពាក្យស្នើសុំក៏ដោយ។

បុគ្គលដែលទទួលបានការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវបង់ថ្លៃការអនុញ្ញាតប្រចាំឆ្នាំ

ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល សម្រាប់ប្រតិបត្តិករនីមួយៗ។ សម្រាប់ឆ្នាំសារពើពន្ធដំបូងនៃការអនុញ្ញាត ប្រតិបត្តិករនីមួយៗត្រូវបង់ថ្លៃការអនុញ្ញាតនៅពេលទទួលបានការអនុញ្ញាត។ សម្រាប់ឆ្នាំសារពើពន្ធបន្តបន្ទាប់ ប្រតិបត្តិករនីមួយៗត្រូវបង់ថ្លៃការអនុញ្ញាតប្រចាំឆ្នាំ យ៉ាងយូរនៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំសារពើពន្ធចាស់។

ជំពូកទី ៤
ភារកិច្ចរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

ប្រការ ១៤.-

បន្ទាប់ពីទទួលបានការអនុញ្ញាត ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវចាប់ផ្តើមសកម្មភាពអាជីវកម្មរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ ដោយគិតចាប់ពីថ្ងៃដែលប្រតិបត្តិករបានទទួលការអនុញ្ញាត។

ប្រការ ១៥.-

ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រត្រូវ ៖

១-ធ្វើប្រតិបត្តិការរបស់ខ្លួនឱ្យដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

២-ត្រួតពិនិត្យ និងគ្រប់គ្រងដោយប្រុងប្រយ័ត្នខ្ពស់រាល់ហានិភ័យដែលកើតឡើងពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ។

៣-បំពេញឱ្យអស់ពីសមត្ថភាពនូវភារកិច្ច ដែលមានចែងនៅក្នុងច្បាប់ អនុក្រឹត្យប្រកាសនេះ និងបទប្បញ្ញត្តិនានា ដោយមិនត្រូវប្រព្រឹត្តអ្វីដែលផ្ទុយពីផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍វិនិយោគិន។

៤-អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានប្រតិបត្តិការរបស់ខ្លួន និងបទប្បញ្ញត្តិជាធរមាន ដែលកំណត់ដោយ **គ.ម.ក.** ធនាគារជាតិនៃកម្ពុជា និងក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

៥-ផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការរបស់ខ្លួន និងប្រាកដថាសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារគោរពតាមវិធានប្រតិបត្តិការ ដើម្បីធានាឱ្យបាននូវសុវត្ថិភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការ និងការពារផលប្រយោជន៍វិនិយោគិន។

90

ប្រការ ១៦.-

ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវធានាឱ្យបាននូវនិរន្តរភាពនៃដំណើរការទីផ្សារមូល-បត្រ និងបំពេញនូវកាតព្វកិច្ចជូនដំណឹង ផ្តល់ព័ត៌មាន និងរក្សាទុកនូវឯកសារ ដូចដែលមានចែងក្នុងជំពូកទី៣ នៃអនុក្រឹត្យ។

ប្រការ ១៧.-

អនុលោមតាមមាត្រា ២៧ នៃអនុក្រឹត្យ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវផ្តល់របាយការណ៍ដែលធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មដែលធ្វើអាជីវកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ប្រការ ១៨.-

ក្រៅពីកាតព្វកិច្ចផ្តល់របាយការណ៍ដូចមានចែងក្នុងជំពូកទី៣នៃអនុក្រឹត្យ ប្រតិបត្តិ-ករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍ផ្សេងទៀត តាមការកំណត់របស់ **គ.ម.ក.**។

ប្រការ ១៩.-

អភិបាល និងបុគ្គលិកគ្រប់រូបរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់ និងមិនត្រូវប្រព្រឹត្តអាកប្បកិរិយាដែលត្រូវបានហាមឃាត់ដូចមានចែងក្នុងជំពូកទី៧ នៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ប្រការ ២០.-

អភិបាលរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូល-បត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រទាំងឡាយណាដែលមានការពាក់ព័ន្ធពីផលប្រយោជន៍តាមគ្រប់រូបភាព ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ក្នុងការធ្វើសេចក្តីសម្រេចណាមួយ ឬក្នុងការអនុម័តកិច្ចសន្យាណាមួយដែលធ្វើឡើងដោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រកាសព័ត៌មាននេះឱ្យបានទូលំទូលាយ ដល់សមាជិកផ្សេងទៀតរបស់ក្រុមប្រឹក្សា-ភិបាល តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលមួយសមស្របមុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដែលនឹងសម្រេចទាក់ទងនឹងបញ្ហានោះ។ អភិបាលដែលមានផល-ប្រយោជន៍ពាក់ព័ន្ធដូចដែលបានរៀបរាប់នេះ មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចប្រជុំ

ក្រុមប្រឹក្សាភិបាល និងមិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតធ្វើសេចក្តីសម្រេចឬក្នុងការអនុម័តកិច្ចសន្យានោះឡើយ។

ប្រការ ២១.-

អភិបាល និងបុគ្គលិកគ្រប់រូបរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ សហព័ទ្ធ បុព្វញាតិ ឬបច្ឆាញាតិរបស់ខ្លួនគិតត្រឹមថ្នាក់ទី៣ មិនត្រូវទទួលអំណោយឬផលប្រយោជន៍តាមគ្រប់រូបភាពពីបុគ្គលដែលខ្លួនមានទំនាក់ទំនងអាជីវកម្មឬហិរញ្ញវត្ថុជាមួយ នៅក្នុងការបំពេញមុខងារនិងតួនាទីរបស់ខ្លួន។

ប្រការ ២២.-

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវបង្កើតឱ្យមានមូលនិធិធានាការទូទាត់សងមួយដាច់ដោយឡែក ដើម្បីធានាការទូទាត់សងនូវរាល់ប្រតិបត្តិការទូទាត់មិនបានសម្រេច។ នីតិវិធីនៃការបង្កើត ការកំណត់ចំនួនទឹកប្រាក់ ការថែរក្សា និងការចាត់ចែងប្រើប្រាស់មូលនិធិនេះត្រូវកំណត់ដោយ **គ.ម.ក.**។

ប្រការ ២៣.-

មុននឹងតែងតាំង ឬផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់ណាមួយ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

ប្រសិនបើតំណែងរបស់បុគ្គលិកជាន់ខ្ពស់ណាមួយនៅទំនេរ ប្រតិបត្តិករត្រូវតែជ្រើសរើសបេក្ខជនថ្មីក្នុងរយៈពេលយ៉ាងយូរ ០២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវឆ្លើយតបទៅនឹងសំណើសុំតែងតាំងបុគ្គលិកជាន់ខ្ពស់នៃប្រតិបត្តិករក្នុងរយៈពេល ០២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំពេញលេញ។ ករណីហួសរយៈពេលកំណត់នេះ សំណើសុំតែងតាំងត្រូវសន្មតថាបានទទួលការយល់ព្រម។

ប្រការ ២៤.-

អនុលោមតាមមាត្រា ២៧ នៃច្បាប់ អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិដឹកនាំកែតម្រូវ ដាក់លក្ខខណ្ឌ ឬដាក់កំហិតបន្ថែម ព្យួរ ឬដកហូតការអនុញ្ញាត ក្នុងករណីដែលប្រតិបត្តិករ៖

១-ទទួលបានការអនុញ្ញាតដោយមធ្យោបាយក្លែងបន្លំណាមួយ។

២-ល្មើសនឹងលក្ខខណ្ឌនៃការអនុញ្ញាត។

៣-ល្មើសនឹងកាតព្វកិច្ចដែលចែងក្នុងប្រកាសនេះ។

៤-មិនធ្វើតាមការណែនាំរបស់ អគ្គនាយកនៃ **គ.ម.ក.** ក្នុងការកែតម្រង់ផ្សេងៗ។

៥-នៅតែបន្តប្រតិបត្តិការក្នុងអំឡុងពេលព្យួរការអនុញ្ញាត។

៦-ផ្អាកប្រតិបត្តិការដោយមិនបានរាយការណ៍ជាមុនទៅអគ្គនាយកនៃ **គ.ម.ក.**។

៧-មិនអាចអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុងទៅបុគ្គលពាក់ព័ន្ធ។

៨-កំពុងស្ថិតនៅក្នុងស្ថានភាពបច្ចេកទេស និង/ឬហិរញ្ញវត្ថុទន់ខ្សោយ ឬកំពុងត្រូវរំលាយដោយគ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត ឬដោយការវិនិច្ឆ័យរបស់តុលាការទៅតាមមូលហេតុស្របច្បាប់។

៩-ប្រព្រឹត្តល្មើសនឹងច្បាប់ អនុក្រឹត្យ ប្រកាសនេះ និងបទប្បញ្ញត្តិផ្សេងទៀត។

ជំពូកទី ៥
ទោសប្បញ្ញត្តិ

ប្រការ ២៥.-

បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិ ដូចមានចែងក្នុងប្រកាសនេះ នឹងត្រូវផ្តន្ទាទោសស្របតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២៦.-

ករណីមានការយឺតយ៉ាវក្នុងការបង់ថ្លៃការអនុញ្ញាត ដូចមានចែងក្នុងប្រការ ១៣ នៃប្រកាសនេះ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវទទួលការផាកពិន័យអន្តរការណ៍ជាប្រាក់ ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ០១ (មួយ) ថ្ងៃ។

ជំពូកទី ៦
អវសានប្បញ្ញត្តិ

ប្រការ ២៧.-

គ.ម.ក. អាចចេញគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹងនិងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

ប្រការ ២៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ២៩.-

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០៩

គាត ឈន់

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា និងសមាជិក **គ.ម.ក.**
- ដូចប្រការ ២៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ៣.០.៨.......អបស.មក

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ មករា ឆ្នាំ២០១០..

លិខិតចូល
ថ្ងៃទី.០១..ខែ.មីនា.ឆ្នាំ២០១០

ប្រកាស

ស្តីពី

បែបបទនិងល័ក្ខខ័ណ្ឌបច្ចេកទេស ក្នុងការសុំបើក ឬបិទ ឬប្តូរទីតាំង នៃមជ្ឈមណ្ឌលកែសម្ផស្ស និង មជ្ឈមណ្ឌលថែរក្សាសម្ផស្ស

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រក/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទនិងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- និងយោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

ស ម្រេ ច

ប្រការ ១.-

ការបើក ការបិទ ការប្តូរទីតាំង ការកែច្នៃទ្រង់ទ្រាយ ការប្តូរអ្នកគ្រប់គ្រងបច្ចេកទេស ការប្តូរនាមករណ៍ នៃមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ ២.-

អាចមានសិទ្ធិសុំបើកមជ្ឈមណ្ឌលកែសម្ផស្សបាន សាមីជនទាំងពីរភេទត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោមៈ

-មានសញ្ជាតិខ្មែរ

-មានសញ្ញាប័ត្រជាវេជ្ជបណ្ឌិតដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងមិនស្ថិតក្នុងក្របខ័ណ្ឌរដ្ឋ

-មិនជាប់ក្នុងបញ្ជីថ្កោលទោសពីបទឧក្រិដ្ឋណាមួយ

-មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន ។

ប្រការ ៣.-

សំណុំលិខិតសុំបើកមជ្ឈមណ្ឌលកែសម្ផស្សមាន :

១-ពាក្យសុំបើក "មានគំរូ"	០១ច្បាប់
២-ច្បាប់ថតចម្លងសញ្ញាប័ត្រវេជ្ជបណ្ឌិត	០១ច្បាប់
៣-ប្រវត្តិសង្ខេបរបស់សាមីជន "មានគំរូ"	០១ច្បាប់
៤-វិញ្ញាបនបត្រសុខភាព	០១ច្បាប់
៥-លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងបញ្ជីគណៈគ្រូពេទ្យ	០១ច្បាប់
៦-លិខិតថ្កោលទោសថ្មី ដែលនៅមានសុពលភាព ចេញដោយក្រសួងយុត្តិធម៌	០១ច្បាប់
៧-គំនូសបំព្រួញទីតាំងមជ្ឈមណ្ឌលកែសម្ផស្ស ដោយមានបញ្ជាក់ពីឃុំ/សង្កាត់	០១ច្បាប់
៨-រូបថតអគារ (ថតពីមុខ និងខាងក្នុង)	០៥សន្លឹក
៩-រូបថតសាមីជន ៤ x ៦ ស.ម	០៧សន្លឹក

សាមីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ចំពោះការសុំបើកសាខានៃមជ្ឈមណ្ឌលកែសម្ផស្ស ត្រូវអនុវត្តតាមបែបបទ និងល័ក្ខខ័ណ្ឌដូចគ្នា នឹងការស្នើសុំបើកមជ្ឈមណ្ឌលកែសម្ផស្សដែរ ។ សាមីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរ សុខាភិបាល រាជធានី-ខេត្ត ។

ប្រការ ៤.-

អាចមានសិទ្ធិសុំបើកមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខាបាន សាមីជនទាំងពីរភេទត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

-មានសញ្ជាតិខ្មែរ

-មានវិញ្ញាបនប័ត្របណ្តុះបណ្តាលអំពីការងារថែរក្សាសម្ផស្សមានរយៈពេលយ៉ាងតិច ០៣ខែ ពីសាលាបណ្តុះបណ្តាលដែលទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច

-មិនជាប់ក្នុងបញ្ជីថ្កោលទោសពីបទឧក្រិដ្ឋណាមួយ

-មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន ។

ប្រការ ៥.-

សំណុំលិខិតសុំបើកមជ្ឈមណ្ឌលថែរក្សាសម្ផស្សមាន :

១-ពាក្យសុំបើក "មានគំរូ"	០១ច្បាប់
២-ច្បាប់ថតចម្លងសញ្ញាប័ត្របណ្តុះបណ្តាលអំពីការងារថែរក្សាសម្ផស្ស	០១ច្បាប់
៣-ប្រវត្តិសង្ខេបរបស់សាម៉ីជន "មានគំរូ"	០១ច្បាប់
៤-វិញ្ញាបនបត្រសុខភាព	០១ច្បាប់
៥-គំនូសបំព្រួញទីតាំងមជ្ឈមណ្ឌលថែសម្ផស្ស ដោយមានបញ្ជាក់ពីឃុំ/សង្កាត់	០១ច្បាប់
៦-លិខិតថ្កោលទោសថ្មី ដែលនៅមានសុពលភាព ចេញដោយក្រសួងយុត្តិធម៌	០១ច្បាប់
៧-រូបថតអគារ (ថតពីមុខ និងខាងក្នុង)	០៥សន្លឹក
៨-រូបថតសាម៉ីជន ៤ X ៦ ស.ម	០៧សន្លឹក

សាម៉ីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ចំពោះការសុំបើកសាខានៃមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ត្រូវអនុវត្តតាមបែបបទ និងល័ក្ខខ័ណ្ឌដូចគ្នា នឹងការស្នើសុំបើកមជ្ឈមណ្ឌលថែរក្សាសម្ផស្សដែរ ។សាម៉ីជនត្រូវបំពេញសំណុំលិខិតខាងលើហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ)តាមរយៈមន្ទីរ សុខាភិបាល រាជធានី-ខេត្ត ។

ប្រការ ៦.-

ការប្តូរទីតាំងនៃមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា ត្រូវបំពេញសំណុំលិខិតដូចខាងក្រោមនេះ :

១-ពាក្យសុំប្តូរទីតាំង "មានគំរូ"	០១ច្បាប់
២-ភ្ជាប់លិខិតអនុញ្ញាតបើក (ច្បាប់ដើម)	០១ច្បាប់
៣-គំនូសបំព្រួញទីតាំងថ្មី ដោយមានបញ្ជាក់ពីឃុំ/សង្កាត់	០១ច្បាប់
៤-រូបថតអាគារ (ថតពីមុខ និងខាងក្នុង) យ៉ាងតិច	០៥សន្លឹក
៥-រូបថតសាម៉ីជន ៤ X ៦ ស.ម	០៧សន្លឹក

សាម៉ីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ប្រការ ៧.-

ការផ្លាស់ប្តូរអ្នកគ្រប់គ្រងបច្ចេកទេស ត្រូវបំពេញសំណុំលិខិតរបស់អ្នកជំនួសដូចខាងក្រោម :

១-ពាក្យសុំផ្លាស់ប្តូរ "មានគំរូ"	០១ច្បាប់
២-សញ្ញាប័ត្រអ្នកជំនួស (ដូចមានចែងក្នុងប្រការ២ និងប្រការ៤)	០១ច្បាប់
៣-ប្រវត្តិសង្ខេបរបស់អ្នកផ្លាស់ចូល "មានគំរូ"	០១ច្បាប់
៤-វិញ្ញាបនបត្រសុខភាព	០១ច្បាប់
៥-លិខិតថ្កោលទោសថ្មី ដែលនៅមានសុពលភាព ចេញដោយក្រសួងយុត្តិធម៌	០១ច្បាប់
៦-លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងបញ្ជីគណៈគ្រូពេទ្យ	០១ច្បាប់
៧-រូបថតសាម៉ីជន ៤ X ៦ ស.ម	០៧សន្លឹក

សាម៉ីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ) តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ប្រការ ៨.-

ក្រសួងសុខាភិបាល នឹងផ្តល់ចម្លើយអំពីការសុំបើក ការសុំបិទ ការប្តូរទីតាំង នៃមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា ដល់សាម៉ីជនយ៉ាងយឺតបំផុតក្នុងរយៈពេល ២០ថ្ងៃ (គិតថ្ងៃធ្វើការ) ដោយគិតចាប់តាំងពីថ្ងៃបានទទួលសំណុំលិខិតគ្រប់គ្រាន់ និងត្រឹមត្រូវនៅនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល។

ប្រការ ៩.-

អ្នកគ្រប់គ្រងបច្ចេកទេសមួយរូប មានសិទ្ធិដាក់ពាក្យសុំបើកមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា បានតែមួយកន្លែងប៉ុណ្ណោះ ។

ប្រការ ១០.-

ក្រោយពីបានទទួលលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ស្តីពីការបើកមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា សាម៉ីជនត្រូវបើកទ្វារបម្រើសាធារណៈជនយ៉ាងយឺតបំផុតរយៈពេល០៣ខែ។ ផុតកំណត់ខាងលើ បើមជ្ឈមណ្ឌលគ្មានដំណើរការទេនោះ លិខិតអនុញ្ញាតត្រូវចាត់ទុកជាមោឃៈដោយស្វ័យប្រវត្តិតាមសេចក្តីសម្រេចរបស់ក្រសួងសុខាភិបាល។ ក្នុងករណីមានមូលហេតុសមស្រប រយៈកាលកំណត់ខាងលើអាចពន្យាពេលបាន ០៣ខែទៀត ហើយបានតែមួយដងគត់តាមសំណើរបស់សាម៉ីជន។

ប្រការ ១១.-

លិខិតអនុញ្ញាតស្តីពីការបើកមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា មានសុពលភាពរយៈពេល០២ឆ្នាំ ។ ពីរខែមុនផុតកំណត់ សាម៉ីជនត្រូវដាក់ពាក្យសុំបន្តសុពលភាពឱ្យបានទាន់ពេលវេលា។ ករណីអស់សុពលភាពក្រសួងសុខាភិបាលនឹងផ្អាកសកម្មភាពជាបណ្តោះអាសន្នរហូតដល់លិខិតអនុញ្ញាតមានសុពលភាពឡើងវិញ។

ប្រការ ១២.-

ចំពោះលិខិតអនុញ្ញាតឱ្យបើកមជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា ដែលបានអស់សុពលភាព ហើយខកខានពុំបានសុំបន្តសុពលភាពចាប់ពី០៣ខែឡើងទៅ ក្រសួងសុខាភិបាលពុំអនុញ្ញាតឱ្យបន្តសុពលភាពបានទេ ហើយលិខិតអនុញ្ញាតនឹងត្រូវចាត់ទុកជាមោឃៈ។

ប្រការ ១៣.-

មជ្ឈមណ្ឌលកែសម្ផស្ស ឬសាខា ត្រូវដាច់ចេញពីកន្លែងស្នាក់នៅ មានអនាម័យស្អាតបាតទាំងខាងក្នុង ទាំងខាងក្រៅ ស្របតាមការកំណត់ដូចខាងក្រោម :

១-ត្រូវមានស្លាកសញ្ញាជាមជ្ឈមណ្ឌលកែសម្ផស្ស

២-មានកន្លែងរង់ចាំទំហំ ២៤ម^2

៣-មានកន្លែងពិគ្រោះទំហំយ៉ាងតិច ១៦ម^2

៤-គ្រែចម្ងាសម្រាប់ពិនិត្យពី ៣ ទៅ ៤

៥-មានបន្ទប់សម្រាប់វះកាត់តូចតាចទំហំយ៉ាងតិច ១៦ម^2 និងបំពាក់ដោយគ្រែវះកាត់ ០១គ្រឿង

៦-មានប្រអប់ប្រដាប់ប្រដាវះកាត់ និងសម្ភារៈសង្គ្រោះបន្ទាន់ត្រឹមត្រូវ

៧-មានចង្កៀងអ៊ុលត្រាវីយ៉ូឡេសម្រាប់រំងាប់មេរោគក្នុងបន្ទប់វះកាត់

៨-មានសម្ភារៈសម្លាប់មេរោគ ឬ Autoclave ឬ Etuve សម្រាប់រំងាប់មេរោគសម្ភារៈវះកាត់ មានសូលុយស្យុង Antiseptique និងចេសដេរដែលមានគុណភាពមិនហួសកាលបរិច្ឆេទ

៩-មានឱសថ និងបរិក្ខាពេទ្យប្រើប្រាស់សមស្រប

១០-មានបន្ទប់ទឹក និងបង្គន់អនាម័យត្រឹមត្រូវ

១១-មានសៀវភៅកត់ត្រាពីសកម្មភាពប្រចាំថ្ងៃ និងត្រូវផ្តល់របាយការណ៍កែសម្ផស្សរៀងរាល់ ០៣ខែ ម្តងជូនទៅនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល។

ប្រការ ១៤.-

មជ្ឈមណ្ឌលថែរក្សាសម្ផស្សឬសាខាត្រូវដាច់ចេញពីកន្លែងស្នាក់នៅ មានអនាម័យស្អាតបាតទាំងខាងក្នុង ទាំងខាងក្រៅ ស្របតាមការកំណត់ដូចខាងក្រោម :

១-ត្រូវមានស្លាកសញ្ញាជាមជ្ឈមណ្ឌលថែរក្សាសម្ផស្ស

២-មានកន្លែងរង់ចាំទំហំ ២០ម^2

៣-មានកន្លែងពិគ្រោះទំហំយ៉ាងតិច ១២ម^2

៤-គ្រែចម្ងាសម្រាប់ពិនិត្យពី ១ ទៅ ២

៥-មានគ្រឿងសម្អាង និងបរិក្ខារប្រើប្រាស់សមស្រប

៦-មានបន្ទប់ទឹក និងបង្គន់អនាម័យត្រឹមត្រូវ

៧-មានសៀវភៅកត់ត្រាពីសកម្មភាពប្រចាំថ្ងៃ និងត្រូវផ្តល់របាយការណ៍ថែរក្សាសម្ផស្សរៀងរាល់ ០៣ខែ ម្តង ជូនទៅនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល ។

ប្រការ ១៥.-

មជ្ឈមណ្ឌលកែសម្ផស្សមានសិទ្ធិដូចតទៅ :

១-កែច្រមុះ

២-វះកាត់ត្របកភ្នែក

៣-ធ្វើថ្គាល់ឱ្យខួច

៤-កែបបូរមាត់

៥-បំបាត់ស្លាកស្នាម

៦-សាក់ភ្នែក សាក់ចិញ្ចើម សាក់បបូរមាត់ លុបសាក់

៧-បណ្តុះសក់

៨-កាត់ប្រជ្រុយ បំបាត់អាចម៍រុយ

៩-បំបាត់ភាពជ្រីវជ្រួញ បំបាត់ជ្រួញកន្ទុយភ្នែក បំបាត់ខ្មៅក្រោមភ្នែក

១០-កែសម្ផស្សដោយប្រើម៉ាស៊ីនឡាស៊ែរ ។

ប្រការ ១៦.-

មជ្ឈមណ្ឌលថែរក្សាសម្ផស្ស មានសិទ្ធិដូចតទៅ :

១-ត្រាំទឹកដោះគោ

២-ខាត់ស្បែកឱ្យសដោយប្រើឡេ

៣-បកស្បែកដោយប្រើថ្នាំពេទ្យ ឬឡេ

៤-ម៉ាស្សាមុខ

៥-ម៉ាស្សាខ្លួន

៦-ស្ទីមមុខ-ខ្លួន

៧-ព្យាបាលមុន មុខជាំ

៨-ពិនិត្យស្បែកមុខ

៩-ពិនិត្យសរសៃសក់

១០-តរោមភ្នែក

១១-ប្រើថ្នាំលេបសម្រកទម្ងន់

១២-ថែរក្សាសម្ផស្សផ្សេងៗទៀត ដោយប្រើថ្នាំពេទ្យ ឬឡេ ឬប្រើម៉ាស៊ីនស៊ីម ឬម៉ាស៊ីនឡាស៊ែរ ដោយពុំមានកែទ្រង់ទ្រាយ និងពុំមានធ្វើការវះកាត់ ។

ប្រការ ១៧.-

បញ្ញត្តិហាមឃាត់ :

១-ហាមផ្សព្វផ្សាយពាណិជ្ជកម្មដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

២-ហាមប្រើប្រាស់គ្រឿងសម្អាងដែលមានប្រភពមិនច្បាស់លាស់ ឬផលិតផលហួសកំណត់កាលប្រើប្រាស់ ឬផលិតផលដែលក្រសួងសុខាភិបាលបានហាមឃាត់

៣-ហាមប្រើប្រាស់ផលិតផលដែលលាយផ្សំក្នុងមជ្ឈមណ្ឌលដោយគ្មានរូបមន្តត្រឹមត្រូវ

៤-ហាមប្រកបអាជីវកម្មផ្សេងៗទៀតនៅក្នុងមជ្ឈមណ្ឌល ឬសាខា ។

ប្រការ ១៨.-

ក្នុងករណីអវត្តមានរបស់អ្នកគ្រប់គ្រងបច្ចេកទេសក្នុងមជ្ឈមណ្ឌល ឬសាខា ត្រូវមានអ្នកបច្ចេកទេសសមស្របមួយរូបមកជំនួស អ្នកជំនួសនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ការជំនួសអាចចូលជាធរមានបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល។

ប្រការ ១៩.-

រយៈកាលនៃការជំនួសមិនអាចលើសពី ០១ឆ្នាំ បានទេ។ ក្នុងករណីចាំបាច់ និងមានមូលហេតុសមស្រប រយៈកាលនៃការកំណត់ខាងលើអាចពន្យាបាន ០១ឆ្នាំ ទៀត តាមសេចក្តីសម្រេចរបស់ក្រសួងសុខាភិបាល។ បែបបទនៃការជំនួស ត្រូវអនុវត្តដូចការសុំផ្លាស់ប្តូរអ្នកគ្រប់គ្រងបច្ចេកទេសដែរ។

ប្រការ ២០.-

មជ្ឈមណ្ឌលកែសម្ផស្ស ឬមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ឬសាខា ដែលមានបញ្ចូលជនបរទេសមកធ្វើការជាមួយ ជនបរទេសទាំងនោះត្រូវគោរពតាមអនុក្រឹត្យលេខ៩៤អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២១.-

ក្រសួងសុខាភិបាលរក្សាសិទ្ធិ ក្នុងការដកហូតមកវិញនូវលិខិតអនុញ្ញាតបើក ប្តូរទីតាំង នៃមជ្ឈមណ្ឌល ឬសាខា ក្នុងករណីពិនិត្យឃើញថា :

១-សាម៉ីជនអនុវត្តមិនបានត្រឹមត្រូវតាមប្រការ១-១៣-១៤-១៥-១៦-១៧-១៨ និងប្រការ២០

២-សាម៉ីជនជាប់ក្នុងបញ្ជីថ្កោលទោសពីទោសឧក្រិដ្ឋណាមួយ។

ប្រការ ២២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ២៣.-

ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានមន្ទីរពេទ្យ មន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងមន្ទីរសុខាភិបាលខេត្ត មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ២៤.-

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចម្លងជូន :

- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ក្រសួងយុត្តិធម៌
- -ក្រសួងទំនាក់ទំនងសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- -ក្រសួងព័ត៌មាន "ដើម្បីជួយផ្សព្វផ្សាយ"
- -សាលារាជធានីភ្នំពេញ និងខេត្ត "ដើម្បីជ្រាបជាព័ត៌មាននិងសហការ"
- -អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
- -អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- -លេខាធិការដ្ឋានគណៈកម្មការអន្តរក្រសួង និងគណៈកម្មការរាជធានី និងខេត្ត លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
- -នាយកដ្ឋានមន្ទីរពេទ្យ "ដើម្បីអនុវត្ត"
- -នាយកដ្ឋានឱសថ
- -មន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងមន្ទីរសុខាភិបាលខេត្ត "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ក្រសួងសុខាភិបាល

ម៉ម ប៊ុនហេង